TROP KHNHOM ទ្រព្យខ្ញុំ

TROP KHNHOM MICROFINANCE PLC.

# របាយការណ៍ប្រចាំឆ្នាំ

# ២០២០

# មាតិកា


១. ទស្សនវិស័យ និងបេសកកម្ម ........ 2
២. គុណតម្លៃ ........ 3
៣. សារវតា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ........ 4
៤. ដំណាក់កាលនៃការវិវត្តន៍របស់ ទ្រព្យខ្ញុំ ........ 5
៥. ព័ត៌មានហិរញ្ញវត្ថុសំខាន់ៗ ........ 6
៦. លទ្ធផលប្រតិបត្តិការ ........ 7
៧. សារពីប្រធានក្រុមប្រឹក្សាភិបាល ........ 10
៨. ភាគទុនិក ........ 13
៩. រចនាសម្ព័ន្ធភាគហ៊ុន ........ 14
១០. ក្រុមប្រឹក្សាភិបាល ........ 15
១១. សន្ទរកថារបស់អគ្គនាយក ........ 20
១២. គណៈកម្មការប្រតិបត្តិ ........ 23
១៣. រចនាសម្ព័ន្ធគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ........ 26
១៤. ការគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុង ........ 27
១៤.១ អភិបាលកិច្ចគ្រប់គ្រងហានិភ័យ ........ 27
១៤.២ ក្របខណ្ឌគ្រប់គ្រងហានិភ័យ ........ 28
១៤.៣ ប្រភេទហានិភ័យ ........ 29
១៥. អភិបាលកិច្ច ........ 34
១៦. សាច់រឿងអតិថិជនជោគជ័យ ........ 37
១៧. ផលិតផល និងសេវាកម្ម ........ 41
១៨. កិច្ចគាំពារអតិថិជន ........ 42
១៩. ឥណទានរៀបចំឡើងវិញ ........ 43
២០. ការចូលរួមបរិច្ចាគថវិកាជួយសង្គម ........ 43
២១. ការគ្រប់ដណ្តប់ប្រតិបត្តិការ ........ 44
២២. លទ្ធផលប្រតិបត្តិការឥណទាន ........ 45
២៣. បណ្តាញសាខា ........ 46
២៤. បណ្តាញសាខា និងតំបន់ប្រតិបត្តិការ ........ 47
២៥. ធនធានមនុស្ស ........ 47
២៦. ការអភិវឌ្ឍន៍ និងកសាងសមត្ថភាពបុគ្គលិក ........ 50
២៧. របាយការណ៍ហិរញ្ញវត្ថុ ........ 52
២៧.១ របាយការណ៍ក្រុមប្រឹក្សាភិបាល ........ 52
២៧.២ របាយការណ៍របស់សវនករឯករាជ្យ ........ 57
២៧.៣ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........ 61
២៧.៤ របាយការណ៍លទ្ធផលពេញលេញ ........ 62
២៧.៥ របាយការណ៍លំហូរសាច់ប្រាក់ ........ 63
២៧.៦ របាយការណ៍បម្រែបម្រួលមូលធន ........ 64
២៨. អាសយដ្ឋានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ........ 65

## ១. ទស្សនវិស័យ និងបេសកកម្ម

### *ទស្សនវិស័យ*

*ទ្រព្យខ្ញុំ គឺជាគ្រឹះស្ថានដែលស្ថិតក្នុងចំណោមអ្នកផ្តល់សេវាហិរញ្ញវត្ថុឈានមុខគេ ដែលចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងសេវាហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋគ្រប់ៗគ្នា។*

### បេសកកម្ម

*ផ្តល់សេវាហិរញ្ញវត្ថុស្របច្បាប់ដែលមានលក្ខណៈរហ័សទាន់ចិត្ត និងប្រកបដោយទំនុកចិត្តដល់អតិថិជនទាំងអស់។*

## ២. គុណតម្លៃ



## ៣. សាខតា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ត្រូវបានបង្កើតឡើងស្ថិតក្រោមទម្រង់ជា **ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** ដោយវិនិយោគិនជនជាតិខ្មែរតាមរយៈការចូលរួមភាគហ៊ុន រវាងក្រុមហ៊ុនក្នុងស្រុកមួយដែលមានឈ្មោះថា Laksmi Prime Investment Co., Ltd ។ គ្រឹះស្ថានបានទទួលអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ ជាមួយដើមទុនបញ្ជីសរុបចំនួន **១,៥០០,០០០ ដុល្លារអាមេរិក**។ បច្ចុប្បន្ននេះ គ្រឹះស្ថានកំពុងតែធ្វើសកម្មភាពប្រតិបត្តិការ ដោយមានការិយាល័យសាខាចំនួន០៤ ក្នុងខេត្តចំនួន០៣ ដែលស្ថិតនៅភាគពាយព្យនៃប្រទេសកម្ពុជា។ គ្រឹះស្ថានមានការិយាល័យចុះបញ្ជីស្ថិតនៅ ផ្ទះលេខ ៤៤៥ ផ្លូវលេខ ៤ ភូមិ សូភី សង្កាត់ កំពង់ស្វាយ ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក មានប្រវត្តិក្នុងការកម្លាយខ្លួន៣ដំណាក់កាលធំៗ ដោយ**លើកទី១** គ្រឹះស្ថានធ្វើប្រតិបត្តិការស្ថិតនៅក្រោមស្លាកយីហោ **ម៉ាយប្រផឹធី ខូ អិលធីឌី** (My Property Co., Ltd) នៅក្នុងឆ្នាំ២០១៣ រហូតដល់ ឆ្នាំ២០១៥។ ស្ថិតក្នុងដំណាក់កាលនោះដែរ សកម្មភាពអាជីវកម្មត្រូវបានធ្វើប្រតិបត្តិការផ្តោតលើ ភតិសន្យាហិរញ្ញវត្ថុដល់អតិថិជន។ **ក្នុងដំណាក់កាលទី២** គ្រឹះស្ថានបានកម្លាយចេញពី**ម៉ាយប្រផឹធី ខូ អិលធីឌី** ទៅជា**ទ្រព្យខ្ញុំ លីស៊ីង ភីអិលស៊ី នៅខែតុលា ឆ្នាំ២០១៥។** ស្ថិតក្នុងដំណាក់កាលនោះគ្រឹះស្ថានទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាជាក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុដែលធ្វើសកម្មភាពប្រតិបត្តិការ ផ្តោតលើភតិសន្យាហិរញ្ញវត្ថុពេញលេញរួមមាន: ការផ្តល់ភតិសន្យាលើចលនវត្ថុដូចជា: ម៉ូតូ គោយន្ត ត្រាក់ទ័រ ម៉ាស៊ីនច្រូតស្រូវ អេស្កាវ៉ាទ័រ គ្រឿងចក្រ រថយន្តតូច និងរថយន្តដឹកទំនិញធុនធំផងដែរ។ **ចំពោះដំណាក់កាលទី៣** គ្រឹះស្ថានបានកម្លាយពីក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុទៅជាគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុនៅឆ្នាំ២០១៧ រហូតមកទាល់បច្ចុប្បន្ននេះ។ ចាប់តាំងពីទទួលបានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរួចមក គ្រឹះស្ថានធ្វើសកម្មភាពប្រតិបត្តិការដោយផ្តោតទៅលើកម្ចីជាសាច់ប្រាក់រួមមាន: កម្ចីកសិកម្ម កម្ចីសម្រាប់ជំនួញ កម្ចីសម្រាប់កែលំអរ លំនៅឋាន កម្ចីជាក្រុម កម្ចីសម្រាប់ទិញម៉ូតូ និងកម្ចីសម្រាប់ទិញរថយន្ត។ ដំណាក់កាលចុងក្រោយ នៅខែមិថុនា ឆ្នាំ២០១៧ **ទ្រព្យខ្ញុំ** បានកម្លាយពី **ទ្រព្យខ្ញុំ លីស៊ីង ភីអិលស៊ី** ទៅជា**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក** ក្រោយពីទទួលបានអាជ្ញាប័ណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា។

គិតត្រឹមខែធ្នូ ឆ្នាំ២០២០ គ្រឹះស្ថានទទួលបានអតិថិជនសកម្មរហូតដល់ **៣,៧៩៨គណនី** រួមជាមួយនឹងផលបត្រកម្ចីដែលមានទឹកប្រាក់រហូតដល់ **៦,១២៨,៧៨១ ដុល្លារអាមេរិក។**



## ៤. ដំណាក់កាលនៃការវិវត្តន៍របស់ ទ្រព្យខ្ញុំ

### ២០១៣-២០១៥

My Property Co., Ltd ជាក្រុមហ៊ុនឯកជនមួយដែលត្រូវបានបង្កើតឡើងស្ថិតក្រោមច្បាប់នៃប្រទេសកម្ពុជា ហើយក្រុមហ៊ុននេះត្រូវបានបង្កើតឡើងនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០១៣ ដែលមានការិយាល័យកណ្តាលស្ថិតនៅខេត្តបន្ទាយមានជ័យ។ ក្រុមហ៊ុនត្រូវបានបង្កើតឡើងដោយស្របច្បាប់ និងចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ដែលមានបញ្ជីកាលេខ Co.0358/2013 នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០១៣។

ក្នុងអំឡុងពេលនោះដែរ សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនគឺផ្តោតទៅលើសកម្មភាពភតិសន្យាហិរញ្ញវត្ថុ។

### ២០១៥-២០១៦

**ទ្រព្យខ្ញុំ លីស៊ីង ភីអិលស៊ី** គឺត្រូវបានកម្លាយចេញពីនាមករណ៍ My Property Co., Ltd បន្ទាប់ពីបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណភតិសន្យាហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា។

ក្រោយមក នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥ ទ្រព្យខ្ញុំទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្មភតិសន្យាហិរញ្ញវត្ថុជាផ្លូវការពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រកបសកម្មភាពភតិសន្យាហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការផ្តល់ផលិតផលភតិសន្យាហិរញ្ញវត្ថុដល់អតិថិជន ដែលមានការិយាល័យកណ្តាលស្ថិតនៅខេត្តបន្ទាយមានជ័យ។

### ២០១៧-២០២០

ចំពោះដំណាក់កាលចុងក្រោយនៃការកម្លាយពី នាមករណ៍ **ទ្រព្យខ្ញុំ លីស៊ីង ភីអិលស៊ី** ទៅជា **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក** បានធ្វើឲ្យមានកំណើនយ៉ាងឆាប់រហ័សចំពោះប្រតិបត្តិការអាជីវកម្ម ដែលកត្តានេះហើយដែលបានជម្រុញឲ្យថ្នាក់គ្រប់គ្រង ហើយនិងក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានសម្រេចចិត្តបន្តស្នើសុំអាជ្ញាប័ណ្ណប្រកបអាជីវកម្ម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា។ ក្រោយមក នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ គ្រឹះស្ថានទទួលបានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីប្រកបសកម្មភាពមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ដែលមានការិយាល័យកណ្តាលស្ថិតនៅខេត្តបន្ទាយមានជ័យ។

## ៥. ព័ត៌មានហិរញ្ញវត្ថុសំខាន់ៗ

| ព័ត៌មានហិរញ្ញវត្ថុសំខាន់ៗ | ខ្នាត | 2020 | 2019 | 2018 |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធ | ពាន់រៀល | (849,924) | 825,206 | 892,182 |
| | ដុល្លារអាមេរិក | (208,468) | 203,654 | 220,564 |
| ផលបត្រកម្ចី | ពាន់រៀល | 24,790,921 | 34,348,872 | 33,051,228 |
| | ដុល្លារអាមេរិក | 6,128,781 | 8,429,171 | 8,225,791 |
| ទ្រព្យសកម្មសរុប | ពាន់រៀល | 34,856,287 | 36,208,857 | 34,849,433 |
| | ដុល្លារអាមេរិក | 8,617,129 | 8,885,609 | 8,673,328 |
| មូលធនសរុប | ពាន់រៀល | 6,869,737 | 7,770,193 | 6,843,225 |
| | ដុល្លារអាមេរិក | 1,698,328 | 1,906,796 | 1,703,142 |
| ប្រាក់ចំណេញសុទ្ធធៀបនឹងមធ្យមភាគទ្រព្យសកម្ម (ROA) | % | -2.40% | 2.30% | 2.60% |
| ប្រាក់ចំណេញសុទ្ធធៀបនឹងមធ្យមភាគមូលធន (ROE) | % | -11.60% | 11.30% | 13.50% |
| អនុបាតសាធនភាព (CAR) | % | 19% | 21% | 20% |
| ស្វ័យភាពគ្រប់គ្រាន់ផ្នែកប្រតិបត្តិការ | % | 90.50% | 114.4% | 113.00% |
| ស្វ័យភាពគ្រប់គ្រាន់ផ្នែកហិរញ្ញវត្ថុ | % | 76.50% | 95.10% | 95.40% |
| អត្រាកម្ចីដែលមានហានិភ័យ (កម្ចីយឺតយ៉ាវ>៣០ថ្ងៃ) | % | 5.30% | 2.60% | 3.00% |
| ភាគរយនៃកម្ចីបាត់បង់ | % | 2.90% | 2.20% | 2.50% |
| ភាគរយនៃអ្នកខ្ចីជាស្ត្រី | % | 39.10% | 38.90% | 37.80% |
| បុគ្គលិកសរុប | | 93 | 91 | 88 |
| ចំនួនអ្នកខ្ចី | | 3,798 | 5,014 | 5,101 |
| ចំនួនខេត្តប្រតិបត្តិការ | | 3 | 3 | 3 |
| ចំនួនស្រុកប្រតិបត្តិការ | | 28 | 28 | 24 |
| ចំនួនឃុំប្រតិបត្តិការ | | 157 | 157 | 142 |
| ចំនួនភូមិប្រតិបត្តិការ | | 810 | 810 | 744 |
| ចំនួនអ្នកខ្ចីធៀបនឹងមន្ត្រីឥណទានម្នាក់ | | 147 | 158 | 148 |
| អត្រាប្តូរប្រាក់ | | 4,045 | 4,075 | 4,018 |

## ៦. លទ្ធផលប្រតិបត្តិការ






អតិថិជនសកម្ម
6,000
5,000
4,000
3,000
2,000
1,000
-
4,252
5,101
5,014
3,798
2017
2018
2018
2020


ផលបត្រកម្ចីសរុប គិតជាលានដុល្លារអាមេរិក
9
8
7
6
5
4
3
2
1
0
7.46
8.23
8.43
6.13
2017
2018
2019
2020


ចំនួនការិយាល័យសាខា
6
5
4
3
2
1
0
1
4
4
5
2017
2018
2019
2020


អត្រាកម្ចីដែលមានហានិភ័យ ( កម្ចីយឺតយ៉ាវ > ៣០ថ្ងៃ )
3.93%
3.03%
2.6%
5.33%
2017
2018
2019
2020

## ៧. សារពីប្រធានក្រុមប្រឹក្សាភិបាល



វិស័យហិរញ្ញវត្ថុបានរីកលូតលាស់យ៉ាងឆាប់រហ័សក្នុងប្រទេសកម្ពុជានៅប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ ការរីកចម្រើននេះ ដោយសារការវិវត្តន៍នៃបច្ចេកវិទ្យាឌីជីថលតាមរយៈការប្រើប្រាស់សេវាកម្មធនាគារដែលកាន់ តែមានភាពងាយស្រួល ហើយនិងបានចូលរួមចំណែកប្រមាណ ២.២% ចំពោះផលិតផលក្នុងស្រុកសរុបនាទសវត្សរ៍ចុងក្រោយនេះ។ ថ្មីៗនេះ សេដ្ឋកិច្ចជាសកលបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចាប់តាំងពីឆ្នាំ២០២០មកដល់បច្ចុប្បន្ននេះ ជាពិសេសគឺវិស័យទេស ចរណ៍ និងវិនិយោគ ដែលទទួលរងនូវផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ។ តាមរយៈការព្យាករណ៍របស់ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាការណ៍ថា អត្រាកំណើននៃសេដ្ឋកិច្ចជាសកលគឺ - **៤.៤%** ស្របពេលដែលអត្រាកំណើននៃផលិតផលក្នុងស្រុកសរុបក្នុងប្រទេសអភិវឌ្ឍត្រូវបានព្យាករណ៍ថា ធ្លាក់ចុះរហូតដល់ -**៥.៨%** និងអត្រាកំណើន - **៣.៣%** ចំពោះប្រទេសកំពុងអភិវឌ្ឍ២០២០។ ផ្អែកលើការព្យាករណ៍នេះ ចំពោះសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា បានកើនឡើងចំនួន៧%នៅមុនឆ្នាំ២០២០។ ក្រោយមកដោយសារទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ហើយសេដ្ឋកិច្ចត្រូវបានព្យាករណ៍ថា ធ្លាក់ចុះរហូតដល់ - ១.៩% ក្នុងឆ្នាំ២០២០។ ប៉ុន្តែនឹងងើបឡើងវិញ ហើយមានអត្រាកំណើនចំនួន ៣.៥% ក្នុងឆ្នាំ២០២១ ហើយយ៉ាងហោចណាស់កើនឡើងដល់៦% ចាប់ពីឆ្នាំ២០២២ បើយោងតាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ត្រូវបានព្យាករណ៍ថា មានអត្រាកំណើន - **២%** ដែលអត្រានេះធ្វើឲ្យផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ថយចុះ រហូតដល់ ១,៦៨៣$ ក្នុងឆ្នាំ២០២០។ បើទោះបីជាយ៉ាងនេះក្ដីវាត្រូវបានព្យាករណ៍ថានឹងមានកំណើនរហូតដល់ **៦.៩%** ក្នុងឆ្នាំ២០២១ ហើយអាចកើនលើសពី**៧%** ចាប់ពីឆ្នាំ២០២២។ ផ្អែកតាមការព្យាករណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ក្នុងប្រទេសកម្ពុជា នឹងអាចកើនលើសពី ២,០០០$ ក្នុងឆ្នាំ២០២៤។

ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានធ្លាក់ចុះដល់ ៨.៤ពាន់លានដុល្លារអាមេរិក នៅក្នុងឆ្នាំ២០២០ ដែលចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានថយចុះពី ៨៣ ស្ថាប័ន ក្នុងឆ្នាំ២០១៩ មកនៅត្រឹម ៨១ស្ថាប័នក្នុងឆ្នាំ២០២០។ ប្រាក់បញ្ញើ និងប្រាក់កម្ចីបានធ្លាក់ចុះដល់២.៦% និង៥.៦% បន្តបន្ទាប់គ្នា បើធៀបនឹងឆ្នាំ២០១៩ ដែលមានអ្នកដាក់ប្រាក់បញ្ញើរហូតដល់ ២.៧លាននាក់ និង អ្នកខ្ចី ១.៩លាននាក់ នៅចុងឆ្នាំ២០២០ ហើយប្រាក់ចំណូល និងប្រាក់ចំណេញសុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅតែបន្តកើនឡើង ជាពិសេសនៅឆ្នាំ២០១៩។

កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានប្រហែល ៦.៨ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០២០ ហើយចំនួននេះទាបជាងឆ្នាំ២០១៩ដែលមានរហូតដល់ ៧.២ ពាន់លានដុល្លារក្នុងឆ្នាំ២០១៩ ដែលស្មើរតែ ១/៣ នៃកម្ចីត្រូវបានផ្ដល់ដល់ក្រុមគ្រួសារអតិថិជន ខណៈដែលវិស័យធំៗរួមមានៈ កសិកម្ម ជំនួញ និងពាណិជ្ជកម្ម និងសេវាកម្មត្រូវបានប្រើប្រាស់ដល់ ៥៦% នៃកម្ចីសរុបផងដែរ។

អត្រាការប្រាក់ជាមធ្យមចំពោះកម្ចី និងប្រាក់បញ្ញើត្រូវបានធ្លាក់ចុះយ៉ាងខ្លាំង ដែលអត្រាការប្រាក់ប្រចាំឆ្នាំចំពោះកម្ចីជាប្រាក់រៀល គឺ១៦.៦% ក្នុងឆ្នាំ២០២០ បានធ្លាក់ចុះពី១៧.៩%ក្នុងឆ្នាំ២០១៩ ស្របពេលដែលកម្ចីជាដុល្លារអាមេរិកមានចំនួន១៤.៩% ក្នុងឆ្នាំ២០២០ បើធៀបនឹងឆ្នាំ២០១៩ គឺមានចំនួន ១៦%។ ចំពោះអត្រាការប្រាក់នៃប្រាក់បញ្ញើជាមធ្យមទាំងប្រាក់រៀល និងដុល្លារមានអត្រាការប្រាក់ដូចគ្នាគឺ ៧.៣%។

សម្រាប់ឆ្នាំ២០២០ គឺជាឆ្នាំមួយដែលធ្វើឲ្យ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បានប្រឈមមុខទៅនឹងផលវិបាកយ៉ាងខ្លាំងក្លា ហើយយើងបានខិតខំពុះពារយ៉ាងពេញទំហឹងដើម្បីទប់ទល់នឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរចំពោះវិស័យហិរញ្ញវត្ថុ និងអាជីវកម្មរបស់យើង។

ក្រុមប្រឹក្សាភិបាលបានធ្វើការរួមគ្នាយ៉ាងសកម្មបំផុតជាមួយនឹងគណៈកម្មការប្រតិបត្តិ និង ថ្នាក់គ្រប់គ្រងដើម្បីកំណត់អត្តសញ្ញាណ និងប្រតិបត្តិវិធានការការពារ និងពង្រឹងភាពធន់របស់គ្រឹះសានផងដែរ។ យើងនៅតែបន្តខិតខំឆ្ពោះទៅរកទស្សនវិស័យ បេសកកម្ម និងទិសដៅជាយុទ្ធសាស្ត្រ ខណៈពេលដែលយើងអនុវត្តគំនិតផ្តួចផ្តើមកាត់បន្ថយចំណាយ រៀបចំបង្កើតគំរូនៃអាជីវកម្មថ្មី និងរចនាសម្ព័ន្ធដែលបានជម្រុញឲ្យយើងអនុវត្តដំណើរការធ្វើសេចក្តីសម្រេចតាមបែបសាមញ្ញ និងឆាប់រហ័ស ហើយឆ្លើយតបឲ្យបានលឿនបំផុតចំពោះលក្ខខណ្ឌទីផ្សារ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បានចូលរួមទប់ស្កាត់យ៉ាងមានប្រសិទ្ធភាព ចំពោះការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលបានបង្ករឡើង ហើយបានបង្កើតនូវវិធីសាស្ត្រដែលមានគំនិតផ្តួចផ្តើមដើម្បីរក្សានិរន្តរភាពសម្រាប់ រយៈពេលវែងផងដែរ។ យើងបានធ្វើការរួមគ្នាជាមួយដៃគូយុទ្ធសាស្ត្រនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចអាជីវកម្មដើម្បីធ្វើឲ្យមានប្រសិទ្ធភាពនៃចំណាយបន្ថែមទៀត ហើយនិងឆ្លើយតបផ្អែកលើបម្រែបម្រួលទីផ្សារ។

ក្រោយពីបានកម្លាយទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពេញលេញ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បានផ្តោតទៅលើការកសាងសមត្ថភាព និងចំណេះដឹងដល់ក្រុមការងារដើម្បីបង្កើនផលិតភាពការងារក្នុងគោលដៅបន្តទស្សនវិស័យក្នុងគោលបំណងផ្តល់បរិយាបន្ន និងសេវាកម្មហិរញ្ញវត្ថុទៅកាន់មនុស្សគ្រប់គ្នាៗ ក្នុងសហគមន៍របស់យើងដើម្បីចូលរួមចំណែកផ្តល់អត្រាកំណើនផលិតផលក្នុងស្រុកសរុបប្រមាណ៣.៥% ក្នុងឆ្នាំ២០២១។

នៅឆ្នាំខាងមុខនេះ យើងមានកិច្ចការជាច្រើនដែលត្រូវធ្វើ ដើម្បីចូលរួមក្នុងវិស័យមីក្រូហិរញ្ញវត្ថុតាមរយៈការពង្រឹងប្រតិបត្តិការក្នុងភូមិសាស្ត្រភាគពាយព្យនៃប្រទេសកម្ពុជា ហើយនៅឆ្នាំខាងមុខ គឺជាឆ្នាំដែលពោរពេញដោយក្តីសង្ឃឹម និងឱកាស។ យើងកំពុងទន្ទឹងរង់ចាំក្នុងការបង្ហាញគំរូអាជីវកម្មល្អៗដោយភាពស្វាហាប់ ដើម្បីឆ្លើយតបទៅនឹងភាពសមស្របនៃទីផ្សារ និងខិតខំបម្រើអតិថិជនក្នុងការផ្តល់ផលិតផល និងសេវាកម្មមីក្រូហិរញ្ញវត្ថុដើម្បីផ្តល់ផលប្រយោជន៍ល្អឥតខ្ចោះដល់ពួកគេទាំងអស់។

ខ្ញុំសូមថ្លែងអំណរគុណចំពោះភាគទុនិក អតិថិជន និងបណ្តាភាគីពាក់ព័ន្ធទាំងអស់ដែលបានបន្តចូលរួមសហការ និងស្មោះត្រង់ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក អស់រយៈពេលជាច្រើនឆ្នាំមកនេះ។ យើងក៏សូមថ្លែងអំណរគុណដល់ធនាគារជាតិនៃកម្ពុជា ដែលបានផ្តល់ការគាំទ្រដល់វិស័យមីក្រូហិរញ្ញវត្ថុអស់រយៈពេលជាច្រើនឆ្នាំផងដែរ។

ខ្ញុំសូមឆ្លៀតយកឱកាសនេះដើម្បីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ សមាជិកក្រុមប្រឹក្សាភិបាល ដែលបានចូលរួមសហការយ៉ាងខ្លាំងក្លា និងផ្តល់យុទ្ធសាស្រ្ត ហើយនិងអនុសាសន៍ដល់ លោក ដាន់ ឈឹង ដែលជាអគ្គនាយក ព្រមទាំងថ្នាក់គ្រប់គ្រងទាំងអស់ និងបុគ្គលិកថ្នាក់ក្រោមទាំងអស់ ដែលដឹកនាំ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ឲ្យកាន់តែខ្លាំងក្លាបន្តទៀត។ បើទោះបីជាដំណាក់កាលបច្ចុប្បន្ននេះស្ថិតក្នុងស្ថានភាពតានតឹងបែបណាក៏ដោយ ក៏យើងនឹងទន្ទឹងរង់ចាំឆ្នាំដែលមានកំណើន និងប្រាក់ចំណេញ ដើម្បីកំណត់ចំណុចគោលនៃវិស័យមីក្រូហិរញ្ញវត្ថុ។

**ដោយក្តីគោរពយ៉ាងកក់ក្តៅ**
**ប្រធានក្រុមប្រឹក្សាភិបាល**



**ខ្សៀម ចាន់សំរេច**

## ៨. ភាគទុនិក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក មានដើមទុនចុះបញ្ជីសរុបចំនួន **៦,០០០លានរៀល** ដែលមានតម្លៃស្មើនឹង **១.៥០០,០០០ដុល្លារអាមេរិក** នៅឆ្នាំ២០១៧ ហើយត្រូវបានបែងចែកជាពីរចំណែកនៅក្នុងចំណោមភាគទុនិកទាំងពីរ។ ភាគទុនិកគឺជាម្ចាស់របស់គ្រឹះស្ថាន ហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក គឺជាក្រុមហ៊ុនវិនិយោគទុនរួមគ្នា រវាងក្រុមហ៊ុនក្នុងស្រុកមួយ ដែលមានឈ្មោះថា Laksmi Prime Investment Co., Ltd និងនិយោគិនក្នុងស្រុកម្នាក់ (**លោក សួរ អ៊ីយ៉ុង**) តាមរយៈគំរូនៃដើមទុនម្នាក់ចំនួន៥០%។ព័ត៌មានលម្អិតនៃភាគទុនិកទាំងពីរមានបង្ហាញដូចខាងក្រោម៖

Laksmi Prime Investment Co., Ltd ហៅថា (Laksmi) ជាក្រុមហ៊ុនមេ (**ក្រុមហ៊ុនហ៊ូលឌីង**) ដែលផ្តោតលើវិស័យធនាគារនៅកម្ពុជា សំដៅទៅលើការវិនិយោគ និង ទទួលទិញស្ថាប័នហិរញ្ញវត្ថុតាមរយៈបំណុល និងមូលប័ត្រកម្មសិទ្ធិ។

- Laksmi គឺត្រូវបានបង្កើតឡើងនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ ដោយ **លោក លឹម សុជាតិ** និងវិនិយោគិនជាស្ត្រីមកពីប្រទេសជប៉ុន
- Laksmi គឺជាក្រុមហ៊ុនត្រួសត្រាយផ្នែកកតិសន្យា និងហិរញ្ញវត្ថុដល់អតិថិជន ក្នុងប្រទេសកម្ពុជា ដោយផ្តល់ផលិតផលហិរញ្ញវត្ថុដ៏សំបូរបែប ដើម្បីបង្កើននូវកម្រិតជីវភាពរស់នៅរបស់ប្រជាជនខ្មែរឲ្យប្រសើរឡើង។
- ការគ្រប់គ្រងមានភាពរឹងមាំខ្លាំង គឺដឹកនាំដោយ**លោក លឹម សុជាតិ** ព្រមទាំងមានការគាំទ្រដោយអ្នកជំនាញផ្នែកប្រតិបត្តិការ នៅតាមគ្រឹះស្ថានហិរញ្ញវត្ថុជាច្រើនផ្សេងៗទៀត។



លោក សួរ អ៊ីយ៉ុង

**លោក សួរ អ៊ីយ៉ុង** គឺជាវិនិយោគិនឯកជនក្នុងស្រុកម្នាក់ដែលបានវិនិយោគរួមគ្នាជាមួយ Laksmi Prime Investment Co., Ltd តាំងពីឆ្នាំ២០១៣ ហើយតាមរយៈរចនាសម្ព័ន្ធភាគហ៊ុន បច្ចុប្បន្ននេះ លោកកំពុងតែកាន់កាប់ភាគហ៊ុនចំនួន៥០% ក្នុងចំណោមភាគហ៊ុនទាំងអស់របស់ក្រុមហ៊ុន។ លោក **សួរ អ៊ីយ៉ុង** មានបទពិសោធន៍ការងារជាច្រើនពាក់ព័ន្ធនឹងកិច្ចការអង្គការមិនមែនរដ្ឋាភិបាល និងការផ្តល់ប្រឹក្សាយោបល់ លើសពីនេះ លោកបានចូលប្រឡូកក្នុងអាជីពការងារជាង១៧ឆ្នាំក្នុងមុខតំណែងជានាយកប្រតិបត្តិអង្គការមិនមែនរដ្ឋាភិបាល និងជាអ្នកផ្តល់ប្រឹក្សាយោបល់ រយៈពេលជាង៣ឆ្នាំផងដែរ។ ចាប់តាំងពីឆ្នាំ២០១៣ រហូតដល់បច្ចុប្បន្ន លោកជាអគ្គនាយកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក។

## ៩. រចនាសម្ព័ន្ធភាគហ៊ុន

| | ភាគទុនិក | ចំនួនភាគហ៊ុន | ដុល្លារអាមេរិក | លានរៀល | ដើមទុនគិតជាភាគរយ |
|---|---|---|---|---|---|
| ១ | លោក សួរ អ៊ីយ៉ុង | ៧៥០,០០០ | ៧៥០,០០០ | ៣,០០០ | ៥០% |
| ២ | Laksmi Prime Investment Co., Ltd | ៧៥០,០០០ | ៧៥០,០០០ | ៣,០០០ | ៥០% |
| សរុប | | ១,៥០០,០០០ | ១,៥០០,០០០ | ៦,០០០ | ១០០% |



## ១០. ក្រុមប្រឹក្សាភិបាល

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក មានមុខងារក្រុមប្រឹក្សាភិបាលមួយ ដែលមានសមត្ថភាពខ្លាំងក្លា និងមានភាពសកម្មនៅក្នុងការងារ។ ក្រុមប្រឹក្សាភិបាលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងគោលបំណងដើម្បីធានាថាគ្រឹះស្ថានបានធ្វើសកម្ម ភាពប្រតិបត្តិការប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ និងបានអនុលោមទៅតាមបទដ្ឋាននៃបទប្បញ្ញត្តិនានា។ ក្រុមប្រឹក្សាភិ បាលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់ការសម្រេចចិត្តលើយុទ្ធសាស្ត្រ ត្រួតពិនិត្យគោលនយោបាយ និងជម្រុញអភិបាលកិច្ចសាជីវកម្មផងដែរ។ ក្រុមប្រឹក្សាភិបាលត្រូវបានតែងតាំងឡើងដោយភាគទុនិក រួមទាំងមានការយល់ព្រម និងទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ផងដែរ។

នៅក្នុងឆ្នាំ២០២០ ក្រុមប្រឹក្សាភិបាលបានបើកកិច្ចប្រជុំស្របទៅតាមកាលវិភាគនៃការប្រជុំប្រចាំឆ្នាំ ដើម្បីពិភាក្សាអំពីប្រតិបត្តិការរួមរបស់គ្រឹះស្ថាន ហើយផ្តល់ជម្រើសក្នុងការដោះស្រាយបញ្ហានានាដែលគ្រឹះស្ថានកំពុងតែប្រឈមមុខ និងបង្កើត យុទ្ធសាស្ត្រស្នូលសម្រាប់ប្រតិបត្តិការយូរអង្វែងរបស់គ្រឹះស្ថាន។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក មានក្រុមប្រឹក្សាភិបាល ដែលពោរពេញដោយសមត្ថភាព និងបទពិសោធន៍ជាច្រើនឆ្នាំ ហើយនៅក្នុងនោះអភិបាលម្នាក់ៗមានចំណេះដឹងទូលំទូលាយ ពាក់ព័ន្ធនឹងភាពជាអ្នកដឹកនាំសាជីវកម្ម ជាពិសេសគឺនៅក្នុងវិស័យហិរញ្ញវត្ថុ។ អភិបាលទាំងអស់គឺជាបុគ្គលដែលមានកម្រិតវប្បធម៌អប់រំខ្ពស់ និងមានកេរ្តិ៍ឈ្មោះល្បីល្បាញដែលត្រូវបានទទួលស្គាល់ដោយ ក្រុមហ៊ុនសាជីវកម្មក្នុងប្រទេសកម្ពុជា។ ក្នុងនោះដែរ ក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក មានសមាសភាពចំនួន០៣រូបសំខាន់ៗដូចខាងក្រោម៖

១.លោក **ឡែម ចាន់សំរេច** ប្រធានក្រុមប្រឹក្សាភិបាល

២. លោក **លឹម សុជាតិ** អភិបាល

៣. លោក **ណា សុធី** អភិបាលឯករាជ្យ

**សម្រាប់តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលរួមមាន៖**

- កំណត់យុទ្ធសាស្ត្រ និងគោលដៅគ្រឹះស្ថាន អនុលោមតាមគោលការណ៍គ្រឹះស្ថាន
- ផ្តល់ទិសដៅជាយុទ្ធសាស្ត្រ និង ត្រួតពិនិត្យ គោលនយោបាយ និងនីតិវិធីនានា
- ត្រួតពិនិត្យលើអភិបាលកិច្ចសាជីវកម្មរបស់គ្រឹះស្ថាន
- ផ្តល់ទិសដៅជាយុទ្ធសាស្ត្រដល់ថ្នាក់គ្រប់គ្រង
- ចូលរួមចំណែកការពារ និងធានានូវនិរន្តរភាពរបស់គ្រឹះស្ថាន។

សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវបានបោះឆ្នោតជ្រើសរើសដោយភាគទុនិក បន្ទាប់មកត្រូវស្នើសុំនូវការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា។ ក្នុងចំណោមអភិបាលទាំងអស់មានប្រធានក្រុមប្រឹក្សាភិបាលចំនួន ០១រូប អភិបាល **០១រូប** និងអភិបាលឯករាជ្យ **០១រូប** ដែលបានប្តេជ្ញាចិត្តខ្លាំងប្រកបដោយឆន្ទៈខ្ពស់ ដើម្បីជម្រុញភាពរីកចម្រើនរបស់គ្រឹះស្ថាន។



លោក ខ្សៀម ចាន់សំរេច
ប្រធានក្រុមប្រឹក្សាភិបាល

**លោក ខ្សៀម ចាន់សំរេច** កំពុងបម្រើការងារជា **នាយកគ្រប់គ្រងទូទៅ នៅ CIC ចាប់តាំងពីឆ្នាំ២០១៣** ហើយលោកមានតួនាទីសំខាន់ៗពាក់ព័ន្ធនឹងៈ អភិវឌ្ឍយុទ្ធសាស្ត្រ និងផែនការហិរញ្ញវត្ថុ ដឹកនាំប្រតិបត្តិការ និងអនុវត្តគម្រោង, ដឹកនាំការគៀរគរមូលនិធិCIC, ស្វែរកឱកាសវិនិយោគថ្មីៗ, ការចូលរួមក្នុងក្រុមហ៊ុនវិនិយោគ, ការរៀបចំរចនាសម្ព័ន្ធ, ការត្រួតពិនិត្យស្ថានភាពក្រុមហ៊ុន, និងយុទ្ធសាស្ត្រចាកចេញ, សម្របសម្រួលជាមួយសមាជិកសហគ្រាសធុនតូច និងមធ្យម, ការបង្កើតអាជីវកម្ម និងភាគីពាក់ព័ន្ធសំខាន់ៗ។

**លោក ខ្សៀម ចាន់សំរេច** មានបទពិសោធន៍ជាច្រើនឆ្នាំពាក់ព័ន្ធនឹងការវិនិយោគ ការគ្រប់គ្រងមូលនិធិ និងការអភិវឌ្ឍសហគមន៍អាជីវកម្មនៃសហគ្រាសធុនតូច និងមធ្យម ហើយលោកមានបទពិសោធន៍រហូតដល់១១ឆ្នាំក្នុង CIC និង ARUN មូលនិធិវិនិយោគសង្គម(ក្រុមហ៊ុនជប៉ុន)។ លោកបានចូលរួមក្នុងការបង្កើតក្រុមហ៊ុន, ការវិនិយោគ និងវិភាគជំនួញ, ការរៀបចំកិច្ចព្រមព្រៀង, ការត្រួតពិនិត្យស្ថានភាពក្រុមហ៊ុន, ការត្រួតពិនិត្យ និងវាយតម្លៃ និងកិច្ចការផ្សេងទៀតជាច្រើន។

លោកជាស្ថាបនិកម្នាក់ក្នុងចំណោមក្រុមស្ថាបនិកសំខាន់ៗដែលបានបង្កើត និង ដំណើរការក្រុមហ៊ុនវិនិយោគសហគមន៍ CIC និងសហគមន៍អាជីវកម្មដែលមានសមាជិកសហគ្រាសធុនតូច និងមធ្យម ជាង៥០០នាក់ចូលរួម ហើយជាអ្នកត្រួសត្រាយមុនគេក្នុងវិស័យគ្រប់គ្រងមូលនិធិក្នុងប្រទេសកម្ពុជា ផងដែរ។

លោកបានចូលរួមនៅក្នុង គម្រោងគោលនយោបាយលើកកម្ពស់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា សហការជាមួយ JICA និង ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបានចូលរួមក្នុងគម្រោងសិក្សាស្រាវជ្រាវអំពី សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាដើម្បីទទួលបានហិរញ្ញវត្ថុ ដែលសិក្សាស្រាវជ្រាវអំពី បញ្ហាប្រឈមសំខាន់ៗ និងឱកាសនានា ដែលគាំទ្រថវិកាដោយ JICA និងអនុវត្តគម្រោងដោយ ARUN ។

លើសពីនេះទៀត **លោក ឡៃម ចាន់សំរេច** បានផ្តល់បច្ចេកទេសដល់សហគមន៍អាជីវកម្ម សហគ្រាសធុនតូច និងមធ្យម តាមរយៈការផ្តល់ប្រឹក្សាយោបល់ និងសកម្មភាពបណ្តុះបណ្តាលទៅកាន់សហគ្រាសធុនតូច និងមធ្យមនៅក្នុងវដ្តការងាររបស់លោក ហើយលោកបានបង្កើតកម្មវិធីពន្លឿនការអភិវឌ្ឍអាជីវកម្ម ឈ្មោះថា BIO Program ដែលកម្មវិធីនេះបានផ្តល់ផលប្រយោជន៍ដល់សហគ្រាសធុនតូច និងមធ្យមជាច្រើននៅក្នុងការពង្រឹងចំណេះដឹង និងសមត្ថភាពគ្រប់គ្រងអាជីវកម្មរបស់ខ្លួន ហើយទទួលបានឱកាសកាន់តែច្រើនក្នុងការទទួលបានប្រភពហិរញ្ញវត្ថុចម្រុះ និងបណ្តាញអ្នកវិនិយោគវ័យក្មេងកម្ពុជា (CAIN) ដើម្បីផ្តល់ចំណេះដឹងវិនិយោគសំខាន់ និងអប់រំដល់អ្នកវិនិយោគឯកត្តបុគ្គលចំពោះពិពិធកម្មផលបត្រវិនិយោគទៅលើសហគ្រាសធុនតូច និងមធ្យម និងការបង្កើតក្រុមហ៊ុន និងសេដ្ឋកិច្ចជាក់ស្តែង។

**លោក ឡៃម ចាន់សំរេច** គឺជាយុវជនកម្ពុជាម្នាក់ដែលមានសុចរិតភាព ភាពជាអ្នកដឹកនាំខ្លាំង ការប្តេជ្ញាចិត្តខ្ពស់ គំនិត ការដោះស្រាយបញ្ហា និងជំនាញទំនាក់ទំនង ហើយលោកបានទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យ Lumière Lyon 2 ក្នុងប្រទេសបារាំង។



**លោក លឹម សុជាតិ**
**អភិបាល**

**លោក លឹម សុជាតិ** ទទួលបានសញ្ញាបត្រគណនេយ្យជំនាញ និងសវនកម្ម (ACCA) នៅឆ្នាំ២០១០, សញ្ញាបត្រគណនេយ្យជំនាញ ហើយនិងសវនកម្មពីប្រទេសអូស្ត្រាលីនៅក្នុងឆ្នាំ២០០៩, សញ្ញាបត្រអ្នកបច្ចេកទេសគណនេយ្យនៅឆ្នាំ២០០៧ និងបរិញ្ញាបត្រសេដ្ឋកិច្ច ជំនាញធនាគារ និងហិរញ្ញវត្ថុនៅឆ្នាំ២០០២។

ចាប់តាំងពីឆ្នាំ២០១២ រហូតមកទាល់បច្ចុប្បន្ននេះ លោកកំពុងបម្រើការងារនៅ Laksmi Prime Investment Co., Ltd ក្នុងមុខតំណែងជាអគ្គនាយកក្រុមហ៊ុន។ មុនពេលលោកចូលបម្រើការងារនៅ Laksmi Prime Investment Co., Ltd លោកធ្លាប់បានធ្វើការនៅ Leopard Capital Cambodia ក្នុងមុខតំណែងជានាយកត្រួតពិនិត្យហិរញ្ញវត្ថុ និង ធ្លាប់ធ្វើការនៅ Morison Kak & Associes ក្នុងមុខតំណែងជាសវនករផងដែរ។



**លោក ណា សុធី**
**អភិបាលឯករាជ្យ**

លោក **ណា សុធី** បានទទួលសញ្ញាបត្រ**អ្នកបច្ចេក ទេសគណនេយ្យ** (CAT) ក្នុងឆ្នាំ២០០៧ និងសញ្ញាបត្រ **ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច** ជំនាញ **គ្រប់គ្រង** ក្នុងឆ្នាំ២០០២។

ចាប់តាំងពីឆ្នាំ២០១៣ រហូតមកទាល់បច្ចុប្បន្នេះ លោកកំពុងបម្រើការងារនៅក្នុង **ក្រុមហ៊ុន** Lim Kim San Import Export and Transportation (Cambodia) Co., Ltd. ដោយកាន់កាប់មុខតំណែងជា **នាយកប្រតិបត្តិ។ មុនពេលចូលបម្រើការងារនៅ** ក្រុមហ៊ុន Lim Kim San Import Export and Transportation (Cambodia) Co., Ltd. លោកធ្លាប់បម្រើការងារនៅ **ក្រុមហ៊ុន** Earnst & Young (Cambodia) Co., Ltd. នៅក្នុងមុខតំណែងជា **ប្រធានសវនករ** ហើយធ្លាប់បានបម្រើការងារនៅ**ក្រុមហ៊ុន** Morison Kak & Associes ក្នុងមុខតំណែងជា **សវនករផងដែរ។**

## ១១. សន្ទរកថារបស់អគ្គនាយក



ខ្ញុំមានក្តីសោមនស្សរីករាយដែលបានបង្ហាញនូវរបាយការណ៍ប្រចាំឆ្នាំ២០២០ ជូនអ្នកទាំងអស់គ្នា។ ឆ្នាំ២០២០ ជាឆ្នាំដែលមានបញ្ហាប្រឈមខ្លាំងក្លា សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក។អស់រយៈពេលស្ទើរតែមួយឆ្នាំពេញ ដែលទ្រព្យខ្ញុំ បានជួបប្រទះនូវការលំបាកជាមួយ នឹងកត្តាបរិយាកាសខាងក្រៅ ដែលបណ្តាលមកពីជំងឺ រាតត្បាតកូវីដ-១៩។ ជំងឺរាតត្បាតនេះគឺជាជំងឺដ៏កាចសាហាវមួយដែលបានឆ្លងរីករាលដាលជាសកលពាសពេញពិភពលោក ដែលបានធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចសកលនិងប្រព័ន្ធសុខភាពសាធារណៈយ៉ាងធ្ងន់ធ្ងរ។ សម្រាប់គ្រឹះ ស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឲ្យ ប្រតិបត្តិការមានការធ្លាក់ចុះយ៉ាងកំហុក អស់រយៈពេលជាច្រើនខែកន្លងមក ដែលបានបង្ខំឲ្យយើង សម្រេចចិត្តផ្អាកនូវការបញ្ចេញកម្ចីដល់អតិថិជន សម្រាប់ការិយបរិច្ឆេទនៃរបាយការណ៍នេះផងដែរ។

នៅក្នុងឆ្នាំ២០២០ យើងមានក្តីមិនពេញចិត្តជាមួយនឹងលទ្ធផលប្រតិបត្តិការ ដែលយើងសម្រេចបាននោះឡើយ។ នេះក៏ដោយសារតែ យើងទទួលបានលទ្ធផលអវិជ្ជមានចំពោះប្រាក់ចំនេញសុទ្ធ និងការធ្លាក់ចុះនៃចំនួនគណនីអតិថិជន និងផលបត្រកម្ចីសរុបដែលយើងពុំធ្លាប់បានជួបប្រទះនោះទេពីមុនមក ចាប់តាំងពីក្រុមហ៊ុនចាប់ផ្តើមបើកដំណើរការប្រតិបត្តិការ រហូតមកទាល់ពេលនេះ។ ដោយសារតែយើងទទួលបានលទ្ធផលបែបនេះ ទើបធ្វើឲ្យយើងមិនអាចពង្រីកប្រតិបត្តិការស្របទៅតាមផែនការដែលគ្រឹះស្ថានបានគ្រោងទុក។ បើទោះបីជាយ៉ាងក៏ដោយ ពួកយើងបានព្យាយាមយ៉ាងលំបាកបំផុត ក្នុងការរក្សានូវស្ថេរភាពនៃប្រតិបត្តិការតាមរយៈកិច្ចខិតខំប្រឹងប្រែង និងពុះពារគ្រប់ឧបសគ្គនៅក្នុងគោលបំណងបន្តទស្សនវិស័យ និងបេសកកម្មរបស់ពួកយើងបន្តទៅថ្ងៃមុខទៀត។

យើងជឿជាក់ថា យើងអាចបង្កើនប្រតិបត្តិការរបស់ពួកយើងសារជាថ្មីឡើងវិញ តាមរយៈការផ្តួចផ្តើមបង្កើតផលិតផលថ្មី និងយុទ្ធសាស្ត្រ ក្នុងគោលបំណងកែប្រែរាល់ចំណុចខ្សោយ និងរកឲ្យឃើញនូវជម្រើសល្អៗសម្រាប់បង្កើនប្រតិបត្តិការអាជីវកម្មរយៈពេលយូរអង្វែង។ ដើម្បីសម្រេចគោលដៅនេះ យើងត្រូវការធនធានមនុស្សល្អៗ និងធ្វើការបំពាក់បំប៉នសមត្ថភាពឲ្យបានខ្លាំងក្លាបន្ថែមទៀត។ ក្រៅពីនេះទៅទៀត យើងប្តេជ្ញាយ៉ាងមុតមាំក្នុងការធ្វើការរួមគ្នា និងសហការជាមួយនឹងក្រុមប្រឹក្សាភិបាល និងភាគទុនិកទាំងអស់ ឲ្យកាន់តែជិតស្និទ្ធបន្ថែមទៀតផងដែរ។

### លទ្ធផលប្រតិបត្តិការប្រចាំឆ្នាំ២០២០

ចំណូលផ្នែកហិរញ្ញវត្ថុរបស់ **ទ្រព្យខ្ញុំ** បានបង្ហាញឲ្យឃើញអំពីការធ្លាក់ចុះចំនួន **១៤.២០%** ដែលមានសាច់ប្រាក់ត្រឹមតែ**១,៧០២,៦៤៧**ដុល្លារអាមេរិកបើប្រៀបធៀបទៅនឹងឆ្នាំ២០១៩ គឺមានចំនួនរហូតដល់**១,៩៨៤,៥១៨ ដុល្លារអាមេរិក**។ វាគឺជាលទ្ធផលប្រាក់ចំណេញអវិជ្ជមាន ដែលយើងមិនធ្លាប់បានជួបប្រទះពីមុនមក ចាប់តាំងពីចាប់ផ្តើមបើក

ប្រតិបត្តិការមក។ លទ្ធផលនេះបណ្តាលមកពីការផ្អាកប្រតិបត្តិការ ក្នុងពេលទទួលរងផលប៉ះពាល់ពីការឆ្លងរីករាលនៃជំងឺកូវីដ-១៩។ ផលបត្រកម្ចីសរុបរបស់យើងបានបង្ហាញឲ្យឃើញអំពីអត្រាថយចុះចំនួន**២៧.២៩%**។ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩។

- **ចំណូលសុទ្ធ:** គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ យើងបានខាតបង់រហូតដល់ចំនួន **២០៨,៤៦៨ ដុល្លារអាមេរិក**។ បញ្ហាប្រឈមនេះ គឺវាកើតចេញពីការផ្អាកបញ្ចេញកម្ចីដល់អតិថិជន អស់រយៈពេលជាច្រើនខែនៅក្នុងឆ្នាំ២០២០ និងការកើនឡើងយ៉ាងខ្លាំងលើសំវិធានធននៃកម្ចីដែលមានហានិភ័យ ក្នុងឆ្នាំ២០២០ ពីអត្រាត្រឹមតែ **២.៦០%** (ឆ្នាំ២០១៩)ហើយបានបន្តកើនឡើងរហូតដល់ **៥.៣០%** (ឆ្នាំ២០២០)។
- **អនុបាតកម្ចីមិនដំណើរការ** បានកើនឡើងពី **២.៦០%** (ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩) រហូតដល់ **៥.៣០%** (ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)។ អត្រាកំណើនទ្វេដងនៃកម្ចីដែលមានហានិភ័យ ត្រូវបានជះឥទ្ធិពលពីការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលបានធ្វើឲ្យអតិថិជនជាច្រើន គ្មានលទ្ធភាពក្នុងការបង់សងត្រឡប់ នេះក៏ដោយសារតែពួកគេបានបាត់បង់ការងារ និងប្រភពចំណូល។ ម្យ៉ាងវិញទៀតនោះ ការធ្លាក់ចុះនៃចំនួនឥណទានសរុប ក៏ជាមូលហេតុដ៏ចម្បងដែលជម្រុញឲ្យអត្រាកម្ចីដែលមានហានិភ័យកើនឡើងខ្លាំងផងដែរ។
- **អតិថិជនសកម្ម:** គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.កទទួលបានអតិថិជន **៣,៧៩៨ គណនី**។ ទិន្នន័យនេះ គឺកើតចេញពីប្រតិបត្តិការចំនួន ០៥ សាខាដែលស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តឧត្តរមានជ័យ
- **ប្រាក់ចំណេញសុទ្ធធៀបនឹងមធ្យមភាគទ្រព្យសកម្ម និងមូលធន (ROA):** ប្រាក់ចំណេញសុទ្ធធៀបនឹងមធ្យមភាគទ្រព្យសកម្ម និង ប្រាក់ចំណេញសុទ្ធធៀបនឹងមធ្យមភាគមូលធនរបស់ **ទ្រព្យខ្ញុំ** បានបង្ហាញអំពីការថយចុះខ្លាំងបើសិនប្រៀបធៀបទៅនឹងឆ្នាំ២០១៩។ ប្រាក់ចំណេញសុទ្ធធៀបនឹងមធ្យមភាគទ្រព្យសកម្មបានថយចុះពី**២.៣០%** (ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩)មកដល់ - **២.៤%** (ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០) និង ប្រាក់ចំណេញសុទ្ធធៀបនឹងមធ្យមភាគមូលធន បង្ហាញពីការថយចុះពី**១១.៣%** (ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩) មកដល់ - **១១.៦%** (ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០) ដែលបុព្វហេតុជាចម្បងនោះ គឺ បណ្តាលមកពីការទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៃវិបត្តិជំងឺកូវីដ-១៩។

## ព័ត៌មានហិរញ្ញវត្ថុសង្ខេបសំខាន់ៗ

| ព័ត៌មានហិរញ្ញវត្ថុសង្ខេប | ខ្នាត | ២០២០ |
|---|---|---|
| ប្រាក់ចំណេញសុទ្ធ | ដុល្លារអាមេរិក | (208,468) |
| ផលបត្រកម្ចី | ដុល្លារអាមេរិក | 6,128,781 |
| ប្រាក់ចំណេញសុទ្ធធៀបនឹងមធ្យមភាគទ្រព្យសកម្ម (ROA) | % | -2.4% |
| ប្រាក់ចំណេញសុទ្ធធៀបនឹងមធ្យមភាគមូលធន (ROE) | % | -11.6% |
| អនុបាតសាធនភាព (CAR) | % | 19% |
| អត្រាកម្ចីដែលមានហានិភ័យ (កម្ចីយឺតយ៉ាវ > ៣០ថ្ងៃ) | % | 5.3% |

## យុទ្ធសាស្ត្រឆ្នាំ២០២១

1. ផ្តោតលើទំហំកម្ចីខ្នាតតូច បង្កើនចំនួនអតិថិជន និងគ្របដណ្តប់តំបន់ប្រតិបត្តិការបន្ថែម
2. កាត់បន្ថយកម្ចីដែលមានស្រាប់ឲ្យតូចជាងមុនដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ
3. ចាត់ទុកឥណទានម៉ូតូជាអាទិភាពជាងគេ

4. បង្កើនការត្រួតពិនិត្យផ្ទៃក្នុងតាមរយៈការបង្កើតគណៈកម្មការសវនកម្មនិងគណៈកម្មការគ្រប់គ្រងហានិភ័យ
5. អនុលោមតាមបទប្បញ្ញត្តិទាំងអស់ដែលបានដាក់ចេញឲ្យអនុវត្តជាធរមាន
6. បន្តពង្រឹងអភិបាលកិច្ចអាជីវកម្ម និងអភិវឌ្ឍសមត្ថភាពបុគ្គលិក
7. ពិចារណាកាត់បន្ថយចំណាយប្រតិបត្តិការ។

**សេចក្តីថ្លែងអំណរគុណ**

ខ្ញុំមានក្តីរំភើបរីករាយយ៉ាងក្រៃលែងដែលត្រូវបានតែងតាំងជា **អគ្គនាយកថ្មី** របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក។ ខ្ញុំសូមប្តេជ្ញាចិត្តក្នុងការរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយនឹងសហការីទាំងអស់ដើម្បីរក្សានូវនិរន្តរភាពនៃប្រតិបត្តិការ ហើយខ្ញុំក៏សូមកោតសរសើរដោយស្មោះចំពោះជំនាញ ការតាំងចិត្ត និងការជឿជាក់ដែលចូលរួមចំណែកដោយសហការីទាំងអស់ដើម្បីពួតដៃគ្នាឆ្ពោះទៅរកភាពជោគជ័យសម្រាប់បច្ចុប្បន្ន និងនាពេលអនាគត។

គិតត្រឹម ខែធ្នូ ឆ្នាំ២០២០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ទទួលបានអតិថិជនសកម្មចំនួន **៣,៧៩៨ គណនី** រួមជាមួយនឹងផលបត្រកម្ចីចំនួន **៦,១២៨,៧៨១ ដុល្លារអាមេរិក**។ ដើម្បីសំដៅឆ្ពោះទៅរកកំណើន និងនិរន្តរភាពរយៈពេលយូរអង្វែង យើងបន្តប្តេជ្ញាចិត្តប្រតិបត្តិតាមយុទ្ធសាស្ត្រអាជីវកម្មដែលដាក់ចេញដោយក្រុមប្រឹក្សាភិបាល ហើយបន្តបង្កើនសេវាហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការអតិថិជន ស្របតាមអ្វីដែលពួកគេបានរំពឹងទុក។ ក្រៅពីនេះ ការពង្រីកគុណភាពនៃការគ្រប់គ្រង និងប្រតិបត្តិការគឺជាទិសដៅអាទិភាព ក្នុងគោលដៅសម្រេចបាននូវប្រាក់ចំណេញផងដែរ។ ស្របពេលជាមួយគ្នានេះដែរ យើងនឹងបន្តរក្សាគុណភាពនៃការផ្តល់សេវាកម្ម ជូនអតិថិជនរបស់ពួកយើង តាមរយៈការពង្រឹងលើការបម្រើសេវាកម្មអតិថិជន និងបន្តផ្តល់សេវាកម្មដែលមានលក្ខណៈរហ័សទាន់ចិត្តដោយស្មើៗភាពគ្នាដល់គ្រប់អតិថិជនទាំងអស់របស់ពួកយើង។

យើងបន្តពង្រឹងកាតព្វកិច្ច និងទំនួលខុសត្រូវសម្រាប់ផ្តល់អត្ថប្រយោជន៍ដល់អ្នកពាក់ព័ន្ធសក្តានុពលទាំងអស់ហើយកិច្ចសហការជាមួយភាគទុនិក ហើយនិងវិនិយោគិនទាំងអស់ នឹងត្រូវបានធ្វើឡើងប្រកបដោយប្រសិទ្ធភាព ក្រោមស្មារតីនៃភាពជាអ្នកដឹកនាំ។ យើងបន្តបង្កើនទំនាក់ទំនងដោយតម្លាភាព ជាមួយបណ្តាភាគីពាក់ព័ន្ធទាំងអស់ដើម្បីផ្តល់ផលប្រយោជន៍ដល់អ្នកទាំងអស់គ្នា ហើយពង្រឹងលើការតាំងចិត្តខ្ពស់ដើម្បីគោរពតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងបន្តកសាងថ្នាក់គ្រប់គ្រងឲ្យមានភាពរឹងមាំខ្លាំងជាងមុនក្នុងគ្រឹះស្ថានទាំងស្រុងផងដែរ។

សម្រាប់ឆ្នាំ២០២១យើងបន្តពង្រឹងលើគុណភាពនៃប្រតិបត្តិការដែលមានស្រាប់ គុណភាពកម្ចី និងផ្តោតទៅលើយុទ្ធសាស្ត្រប្រាក់ចំណេញ។ លើសពីនេះទៀតយើងនឹងពិចារណាក្នុងការប្រើប្រាស់នូវធនធានដែលគ្រឹះស្ថានមានឲ្យអស់ពីលទ្ធភាព នៅក្នុងគោលដៅរក្សាចំណាយឲ្យមានប្រសិទ្ធភាព និងភាពនាំមុខនៃថ្លៃដើមរយៈពេលយូរអង្វែងទៀតផង។

ជាចុងក្រោយ ខ្ញុំក៏សូមថ្លែងអំណរគុណបន្តដល់ក្រុមប្រឹក្សាភិបាលដែលបានផ្តល់ជាយោបល់ និងទិសដៅដ៏មានតម្លៃដល់ថ្នាក់គ្រប់គ្រង ហើយក៏សូមថ្លែងអំណរគុណដល់បុគ្គលិក ក្រុមប្រឹក្សាភិបាល ភាគទុនិក ដៃគូវិនិយោគ បញ្ញត្តិករ អាជ្ញាធរ មូលដ្ឋាន អតិថិជន និងបណ្តាភាគីពាក់ព័ន្ធទាំងអស់ដែលតែងតែចូលរួមក្នុងការសហការ និងគាំទ្ររហូតមកទាល់សព្វថ្ងៃនេះ។

**អគ្គនាយក**

**ជាន់ ឈឹង**

## ១២. គណៈកម្មការប្រតិបត្តិ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក មានគណៈកម្មការប្រតិបត្តិដែលខ្លាំងក្លា និងសកម្ម ដែលមុខងារនេះបានដើរតួនាទីក្នុងការដឹកនាំ និងតម្រង់ទិសដៅប្រតិបត្តិការទាំងស្រុងក្នុងគ្រឹះស្ថាន។គណៈកម្មការនេះមានសមាសភាពចំនួន០៥រូបដែលមានជំនាញផ្សេងៗគ្នា ក្នុងនោះរួមមានៈ អគ្គនាយក នាយកប្រតិបត្តិការ ប្រធានហិរញ្ញវត្ថុ និងនាយកសាខា។ សម្រាប់ការអនុវត្តការងារប្រចាំថ្ងៃ គណៈកម្មការនេះដើរតួជាបណ្តោះអាសន្នជំនួសឲ្យក្រុមប្រឹក្សាភិបាលនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តចំពោះការងារដែលមានលក្ខណៈបន្ទាន់ខ្លាំង។ ចំពោះតួនាទីគណៈកម្មការនេះរួមមានៈ ផ្តល់យោបល់ ត្រួតពិនិត្យលើលទ្ធផលប្រតិបត្តិការ អភិវឌ្ឍគោលនយោបាយ រៀបចំផែនការយុទ្ធសាស្ត្រ រៀបចំផែនការវិនិយោគ និងគ្រប់គ្រងហានិភ័យផងដែរ។ សម្រាប់សមាសភាពរបស់គណៈកម្មការប្រតិបត្តិមានបង្ហាញលំអិតដូចខាងក្រោមៈ



លោក **ដាន់ ឈឹង**
**អគ្គនាយក**

**លោក ដាន់ ឈឹង** ទទួលបានសញ្ញាបត្រ**បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម** ជំនាញ**គ្រប់គ្រង** ក្នុងឆ្នាំ២០១១ (**សាកលវិទ្យាល័យបៀលប្រាយ**) និងសញ្ញាបត្រ**បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម** ជំនាញ **គ្រប់គ្រង** នៅឆ្នាំ២០០៧ (វិទ្យាស្ថានកម្ពុជា)។ ក្រៅពីកម្រិតអប់រំថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់** និងថ្នាក់**បរិញ្ញាបត្រ** លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាំងនៅក្នុង និងក្រៅប្រទេសដូចជាៈ ការអភិវឌ្ឍសហគមន៍, ឥណទានជនបទ, ភាពជាអ្នកដឹកនាំ, ការធ្វើផែនការអាជីវកម្ម, ធានារ៉ាប់រងសុខភាពខ្នាតតូច, ការពង្រីកបណ្តាញសាខា, និងប្រព័ន្ធហិរញ្ញប្បទានសុខភាព។ លោកបានបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ចាប់តាំងពីឆ្នាំ២០១៣ ក្នុងមុខតំណែងជា**នាយកចាត់ការទូទៅ**។

មុនពេលចូលបម្រើការងារនៅ**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក** លោកធ្លាប់មានបទពិសោធន៍ការងារនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល អស់រយៈពេលជាង១៥ឆ្នាំ ហើយធ្លាប់កាន់កាប់មុខតំណែងជាច្រើនដូចជា ភ្នាក់ងារឥណទានជនបទ, មន្ត្រីអភិវឌ្ឍន៍សហគមន៍, នាយករង, អ្នកប្រឹក្សាយោបល់គម្រោង, និងប្រធានគម្រោងធានារ៉ាប់រងសុខភាពសហគមន៍ ផងដែរ។ លោកបានទទួលសញ្ញាបត្រ**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់** នៅឆ្នាំ២០១១។



**លោក អៀម វាសនា**
**ប្រធានហិរញ្ញវត្ថុ**

**លោក អៀម វាសនា** ទទួលបានសញ្ញាបត្រ**បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម** ជំនាញ**ហិរញ្ញវត្ថុ និងធនាគារ** ក្នុងឆ្នាំ២០១២ ហើយលោកបានចូលរួមនូវវគ្គបណ្តុះបណ្តាលជាច្រើនដូចជា ការអភិវឌ្ឍសហគមន៍ ការធ្វើផែនការអាជីវកម្ម ជំនាញពន្ធដារ ជំនាញគណនេយ្យ និងការគ្រប់គ្រងសាច់ប្រាក់។ **លោក អៀម វាសនា** បានចូលបម្រើការងារក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ចាប់តាំងពីឆ្នាំ២០១៣ ក្នុងមុខតំណែងជាគណនេយ្យករ, ប្រធានគណនេយ្យ និងប្រធានហិរញ្ញវត្ថុ។

មុនពេលបម្រើការងារក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក **លោក អៀម វាសនា** ធ្លាប់បានបម្រើការ ងារជាមន្ត្រីឥណទាន នៅសមាគមផ្តើមគំនិតពាណិជ្ជកម្ម (ABI) និង អង្គការគ្រួសារសង្គ្រោះ និង ស្ត្រីមេម៉ាយកម្ពុជា (CAAFW)។



**លោក សោម ហ៊ុយ**
**នាយកសាខា**

**លោក សោម ហ៊ុយ** បានបញ្ចប់ការសិក្សា**កម្រិតមធ្យមសិក្សាទុតិយភូមិ**ហើយលោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន ដូចជា៖ ការគ្រប់គ្រងសាខា, ការពង្រីកបណ្តាញប្រតិបត្តិការ, ការលួចគៃបន្លំក្នុងការ ផ្តល់កម្ចី, ការគ្រប់គ្រងហានិភ័យ, ការថែរក្សាអតិថិជន, ការអនុវត្តធ្វើផែន ការ និងត្រួតពិនិត្យតាមដាន និងវគ្គបណ្តុះបណ្តាលផ្សេងទៀតផងដែរ។

**លោក សោម ហ៊ុយ** បានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ក្នុងឆ្នាំ២០១៣ ហើយដំបូងឡើយ លោកបានកាន់កាប់មុខតំណែងជាមន្ត្រីឥណទាន។ ក្រោយមកលោកត្រូវបានតំឡើងឋានៈជាប្រធានឥណទាន, នាយកសាខា និងជំនួយការនាយកចាត់ការទូទៅ ហើយមុនពេលចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក លោកធ្លាប់បានបម្រើការងារ អស់រយៈពេលជាច្រើនឆ្នាំក្នុងអង្គការគ្រួសារសង្គ្រោះ និង ស្ត្រីមេម៉ាយកម្ពុជា (CAAFW) ក្នុងមុខតំណែងជាមន្ត្រីឥណទាន។



លោក ឈូក សុជាតិ
នាយកសាខា

**លោក ឈូក សុជាតិ** ទទួលបានសញ្ញាបត្រ **បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម** ជំនាញ **គ្រប់គ្រង** នៅឆ្នាំ ២០០៨ ពីសាកលវិទ្យាល័យបៀលប្រាយ ហើយលោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដូចជា:ការគ្រប់គ្រងសាខា ,ការលួចគៃបន្លំក្នុងការផ្តល់កម្ចី និង វគ្គបណ្តុះបណ្តាលជាច្រើនផ្សេងៗទៀត។

លោក **ឈូក សុជាតិ** បានចូលបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ចាប់តាំងពីឆ្នាំ២០១៤ ក្នុងមុខតំណែងជាមន្ត្រីឥណទាន ក្រោយមកលោកត្រូវបានតំឡើងឋានៈជា ប្រធានឥណទាន និងនាយកសាខា។ មុនពេលបានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក លោកធ្លាប់មានបទពិសោធន៍បម្រើការងារនៅ មន្ទីរពន្ធដារខេត្ត និងជាមន្ត្រីឥណទាន នៅក្នុង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ (PRASAC) ផងដែរ។



លោក សួង សីហា
មន្ត្រីប្រតិបត្តិតាម

លោក **សួង សីហា** បានទទួលសញ្ញាបត្រ**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់** ជំនាញ:**គ្រប់គ្រងទូទៅ** ក្នុងឆ្នាំ២០១៨ និង**សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ជំនាញ:គ្រប់គ្រង** ក្នុងឆ្នាំ ២០១៥ (ពីសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច)។ ក្រៅពីសមិទ្ធិផលអប់រំកម្រិតថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ និង ថ្នាក់បរិញ្ញាបត្រ** លោកបានចូលរួមក្នុងវគ្គ បណ្តុះបណ្តាលជាច្រើន រួមមាន: ការប្រតិបត្តិតាមបទប្បញ្ញត្តិ, គោលការណ៍ការពារអតិថិជន, ការគ្រប់គ្រងលទ្ធផលប្រតិបត្តិការនៅក្នុងសង្គម, ការបណ្តុះបណ្តាលអ្នកហ្វឹកហ្វឺន, ការប្រឆាំងការសម្អាតប្រាក់និង ហិរញ្ញប្បទានភេរវកម្មនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ, ការគ្រប់ គ្រងទូទៅ, ប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទានឲ្យទទួលបានផលបត្រកម្ចីដែលមានសុខភាពល្អ, គន្លឹះក្នុងការថែរក្សាអតិថិជន, ការធ្វើផែនការ និងត្រួតពិនិត្យតាមដាន ហើយនិងប្រតិបត្តិការរបស់ផ្សារមូលបត្រកម្ពុជា។

លោក **សួង សីហា** បានចូលបម្រើការងារនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.កនៅឆ្នាំ២០១៥ ក្នុងមុខតំណែងជាមន្ត្រីឥណទាន។ ក្រោយមក លោកត្រូវបានតំឡើងឋានៈជា ប្រធានឥណទាន មន្ត្រីគ្រប់គ្រងធនធានមនុស្ស និងជាមន្ត្រីប្រតិបត្តិតាម។ មុនពេលចូលបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក លោកធ្លាប់បានបម្រើការងារជា មន្ត្រីឥណទាន អស់រយៈពេលជាច្រើនឆ្នាំ នៅ និរន្តរ ទីភ្នាក់ងារអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ (NIRON) និងនៅ អង្គការគ្រួសារសង្គ្រោះ និងស្ត្រីមេម៉ាយកម្ពុជា (CAAFW) ផងដែរ។

## ១៣. រចនាសម្ព័ន្ធគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក



## ១៤. ការគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុង

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បានបង្កើតក្របខណ្ឌអភិបាលកិច្ច និងគ្រប់គ្រងហានិភ័យដ៏សមស្រប ដើម្បីបង្កើនការត្រួតពិនិត្យផ្ទៃក្នុង និងរក្សាសុវត្ថិភាពប្រតិបត្តិការពីកត្តាហានិភ័យផ្ទៃក្នុង និងផ្នែកខាងក្រៅណាមួយ ដែលអាចកើតឡើងហើយអភិបាលកិច្ចគ្រប់គ្រងហានិភ័យ គឺស្ថិតក្រោមការត្រួតពិនិត្យដោយក្រុមប្រឹក្សាភិបាល។ មុខងារអភិបាលកិច្ចគ្រប់គ្រងហានិភ័យ តាមរយៈក្របខណ្ឌគ្រប់គ្រងហានិភ័យ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុង ការកំណត់អត្តសញ្ញាណ និងការពារហានិភ័យនានាដែលអាចកើតមានឡើងក្នុងគ្រឹះស្ថាន។

ដើម្បីគ្រប់គ្រងហានិភ័យទាំងអស់នោះ គ្រឹះស្ថានបានបែងចែកតួនាទីដាច់ដោយឡែកពីគ្នាសម្រាប់បុគ្គល ដែលមានការទទួលខុសត្រូវ ដោយផ្ទាល់ដែលមានតួនាទី ក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចគ្រប់គ្រងហានិភ័យរបស់យើង។មុខងារទាំងអស់នោះរួមមានៈ អគ្គនាយក មន្ត្រីសវនកម្មផ្ទៃក្នុង មន្ត្រីប្រតិបត្តិតាម គណៈកម្មការប្រតិបត្តិ និង នាយកសាខា។ យើងបានផ្តោតសំខាន់ទៅលើប្រភេទហានិភ័យដូចជាៈ ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យសាច់ប្រាក់ងាយស្រួល ហានិភ័យផ្នែកទីផ្សារ ហានិភ័យផ្នែកប្រតិបត្តិតាម ហានិភ័យផ្នែកបទប្បញ្ញត្តិ និង ហានិភ័យផ្នែកកេរ្តិ៍ឈ្មោះ។ ដើម្បីគ្រប់គ្រងហានិភ័យទាំងអស់នេះ គឺយើងត្រូវពង្រឹងលើអភិបាលកិច្ចអាជីវកម្ម តាមរយៈការអនុវត្តគោលនយោបាយ និងនីតិវិធីពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ។

### ១៤.១ អភិបាលកិច្ចគ្រប់គ្រងហានិភ័យ

រចនាសម្ព័ន្ធខាងក្រោម ជារចនាសម្ព័ន្ធអភិបាលកិច្ចគ្រប់គ្រងហានិភ័យរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក វាបង្ហាញពីស្ថាប័នអភិបាលកិច្ច និងមុខងារដែលជាប់ពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងហានិភ័យដែលមានការបែងចែកតួនាទី និងភារកិច្ចច្បាស់លាស់ហើយរចនាសម្ព័ន្ធអភិបាលកិច្ចគ្រប់គ្រងហានិភ័យមានបង្ហាញដូចខាងក្រោមៈ




ចំពោះការបែងចែកតួនាទី និងការទទួលខុសត្រូវនៃមុខងារនីមួយៗត្រូវបានបង្ហាញលំអិតដូចខាងក្រោមៈ

**ក្រុមប្រឹក្សាភិបាល**

- បង្កើត និងអនុម័តគោលនយោបាយ និងនីតិវិធីស្តីពីការគ្រប់គ្រងហានិភ័យ
- បង្កើតយុទ្ធសាស្ត្រ និងទិសដៅដើម្បីទប់ស្កាត់ហានិភ័យ
- តាមដាន និងត្រួតពិនិត្យលើការគ្រប់គ្រងហានិភ័យ
- សិក្សា និងវាយតម្លៃអំពីហានិភ័យធំៗនានាដែលអាចកើតមានឡើងក្នុងបរិបទ **ទ្រព្យខ្ញុំ**

**អគ្គនាយក**

- អនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យឲ្យមានប្រសិទ្ធភាព
- ធានាថា គោលនយោបាយគ្រប់គ្រងហានិភ័យត្រូវបានអនុវត្តយ៉ាងពេញលេញដោយបុគ្គលិកទាំងអស់
- ធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការសវនកម្ម គណៈកម្មការគ្រប់គ្រងហានិភ័យ ប្រធានសវនកម្មផ្ទៃក្នុង និងមន្ត្រីប្រតិបត្តិតាម ដើម្បីកំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យនានា
- កសាងវប្បធម៌នៃការគ្រប់គ្រងហានិភ័យក្នុងគ្រឹះស្ថាន។

**ប្រធានសវនកម្មផ្ទៃក្នុង**

- អនុវត្តសកម្មភាពត្រួតពិនិត្យផ្ទៃក្នុងជាប់លាប់លើផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការ
- ផ្តល់ការធានាលើការអនុវត្តតួនាទីសវនកម្មផ្ទៃក្នុង
- កំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យធំៗពាក់ព័ន្ធនឹងប្រតិបត្តិការហិរញ្ញវត្ថុ
- លើកឡើង និងផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងនីតិវិធីគ្រប់គ្រងហានិភ័យ
- រាយការណ៍ភ្លាមៗអំពីហានិភ័យ និងកំហុសធ្ងន់នានាដែលបានរកឃើញ ជូនគណៈកម្មការសវនកម្ម និងគណៈកម្មការគ្រប់គ្រងហានិភ័យ
- វាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យ។

**គណៈកម្មការប្រតិបត្តិ**

- កំណត់អត្តសញ្ញាណ និងវាយតម្លៃឥតឈប់ឈរអំពីហានិភ័យផ្នែកយុទ្ធសាស្ត្រ
- អភិវឌ្ឍគោលនយោបាយគ្រប់គ្រងហានិភ័យ
- បង្កើតយុទ្ធសាស្ត្រ និងក្របខណ្ឌគ្រប់គ្រងហានិភ័យ និងផ្តល់បច្ចេកទេសគាំទ្រនានា
- ត្រួតពិនិត្យតាមដានលទ្ធផលនៃការគ្រប់គ្រងហានិភ័យ
- បង្កើតដំណោះស្រាយ និងជម្រើសនានាក្នុងការដោះស្រាយហានិភ័យ
- រាយការណ៍អំពីហានិភ័យ។

**មន្ត្រីប្រតិបត្តិតាម**

- កំណត់ហានិភ័យដែលប៉ះពាល់ដោយសារការមិនប្រតិបត្តិតាមបទប្បញ្ញត្តិ
- សហការជិតស្និទ្ធជាមួយប្រធានគ្រប់គ្រងហានិភ័យដើម្បីបង្កើតយុទ្ធសាស្ត្រ និងយន្តការគ្រប់គ្រងហានិភ័យ
- រាយការណ៍អំពីហានិភ័យធំៗដែលកើតមានក្នុងប្រតិបត្តិការគ្រឹះស្ថាន
- ធានាថា គ្រឹះស្ថានបានអនុលោមតាមគោលនយោបាយ និងបទប្បញ្ញត្តិនានាដែលបានដាក់ចេញឲ្យគ្រឹះស្ថានអនុវត្តជាធរមាន។

## ១៤.២ ក្របខណ្ឌគ្រប់គ្រងហានិភ័យ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បានជ្រើសរើសយកដំណាក់កាលចំនួន០៤យ៉ាង សម្រាប់ក្របខណ្ឌគ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថាន។ ការធ្វើបែបនេះនឹងផ្តល់គោលការណ៍ណែនាំ សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត និងបង្កើតដំណើរការគ្រប់គ្រងហានិភ័យនៅក្នុងគ្រឹះស្ថានរបស់យើង។ ក្របខណ្ឌនេះនឹងក្លាយជាដំណាក់កាលដ៏ច្បាស់លាស់មួយសម្រាប់អ្នកធ្វើសេចក្តីសម្រេចដែលពាក់ព័ន្ធ នៅក្នុងគោលនយោបាយគ្រប់គ្រងហានិភ័យនេះ។ សមាសធាតុសំខាន់ៗនៃក្របខណ្ឌនេះរួមមានៈ ការកំណត់អត្តសញ្ញាណហានិភ័យ ការសិក្សា និងវាយតម្លៃហានិភ័យ ការវាស់វែងហានិភ័យ និងការគ្រប់គ្រងហានិភ័យ។ ព័ត៌មានខាងក្រោមនេះជាក្របខណ្ឌគ្រប់គ្រងហានិភ័យៈ




## ១៤.៣ ប្រភេទហានិភ័យ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បានកំណត់ថា មានហានិភ័យចំនួន០៧ប្រភេទ ដែលគ្រឹះស្ថានបានកំណត់ថា នឹងអាចមានលទ្ធភាពកើតមានឡើងក្នុងប្រតិបត្តិការរបស់គ្រឹះស្ថាន ហើយហានិភ័យទាំងនោះរួមមានៈ **ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យសាច់ប្រាក់ងាយស្រួល ហានិភ័យទីផ្សារ ហានិភ័យផ្នែកកេរ្តិ៍ឈ្មោះ ហានិភ័យផ្នែកប្រតិបត្តិតាម និងហានិភ័យផ្នែកបទប្បញ្ញត្តិ**។ នៅក្នុងស្ថានភាពបច្ចុប្បន្ននេះ **ទ្រព្យខ្ញុំ** ចាត់ទុកហានិភ័យទាំងនេះ ជាហានិភ័យដែលត្រូវបានចាត់ជាអាទិភាពរបស់យើង។ ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងលើហានិភ័យទាំងនោះ យើងបានបង្កើតនូវគោលនយោបាយគ្រប់គ្រងហានិភ័យដ៏សមស្រប ដែលបានផ្តល់សេចក្តីណែនាំច្បាស់លាស់ ដល់អ្នកធ្វើសេចក្តីសម្រេចចិត្តរបស់ **ទ្រព្យខ្ញុំ** នៅក្នុងការអនុវត្តតាមផងដែរ។ គោលនយោបាយនេះត្រូវបានរៀបចំឡើងដោយមានយុទ្ធសាស្ត្រ និងយន្តការក្នុងការគ្រប់គ្រងហានិភ័យគ្រប់គ្រាន់ព្រមទាំងវិធានការបែបប្រុងប្រយ័ត្នដើម្បីគ្រប់គ្រងលើហានិភ័យទាំងនោះ។ ព័ត៌មានស្តីពីហានិភ័យនីមួយៗត្រូវបានបង្ហាញដូចខាងក្រោមៈ

### ហានិភ័យឥណទាន

**ហានិភ័យឥណទាន** គឺត្រូវបានកំណត់អត្តសញ្ញាណ និងទទួលស្គាល់ថា ជាហានិភ័យធំជាងគេបំផុតនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ហើយចំពោះប្រតិបត្តិការ និងការអនុវត្តរបស់យើងហានិភ័យឥណទានគឺជាហានិភ័យមួយដែលមានលក្ខណៈស្មុគស្មាញបំផុត ដែលចាំបាច់ត្រូវចាត់វិធានការ កំណត់អត្តសញ្ញាណ វិភាគ ហើយត្រួតពិនិត្យជាបន្តបន្ទាប់ឥតឈប់ឈរ។ ជាទូទៅហានិភ័យឥណទាន គឺយើងផ្តោតទៅលើវិធីការពារកម្ចីឃើតយ៉ាវ ការសំរិតសំរាំងជ្រើសរើសអតិថិជន ការប្រមូលឥណទានត្រឡប់មិនបាន ការគៃបន្លំ និងការឃុបឃិតផ្តល់កម្ចី។ ឆ្លើយតបនឹងហានិភ័យឥណទាននេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បានគិតគូរបង្កើតនូវវិធានការ និងវិធីសាស្ត្រឆ្លើយតបហានិភ័យឥណទាន ដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតមានឡើងដូចខាងក្រោមៈ

## គោលនយោបាយឥណទាន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បានបង្កើតគោលនយោបាយឥណទានដែលផ្តល់នូវគោលការណ៍ណែនាំ និងនីតិវិធីនានានៅក្នុងការសិក្សា និងវាយតម្លៃកម្ចីផងដែរ។ គោលនយោបាយនេះត្រូវបានត្រួតពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ហើយគោលនយោបាយនេះបានផ្តល់នូវព័ត៌មានលំអិត អំពីយន្តការ និងវិធីសាស្ត្រក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យឥណទានផងដែរ។ ម្យ៉ាងវិញទៀត វាក៏មានបង្ហាញអំពីការវាយតម្លៃកម្ចី នីតិវិធីវាយតម្លៃ ការគ្រប់គ្រង និងរក្សាទុកឯកសារកម្ចីផងដែរ។ លើសពីនេះទៀតក៏មានចែងពីទំហំកម្ចី សិទ្ធិអំណាចសម្រេចកម្ចី ជម្រើសនៃការសងប្រាក់ កាតព្វកិច្ចអតិថិជន ហើយគោលនយោបាយនេះ ត្រូវបានបណ្តុះបណ្តាលដល់បុគ្គលិក និងមុខងារទាំងអស់ក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បានយល់ដឹងផងដែរ។

## គណៈកម្មការឥណទាន

គោលនយោបាយឥណទាន គឺបានកំណត់ពីមុខងារនៃគណៈកម្មការឥណទាន ដែលមានតួនាទីត្រួតពិនិត្យដំណើរការសិក្សា និងវាយតម្លៃកម្ចី ពិនិត្យឡើងវិញ និងអនុម័តកម្ចីដែលស្ថិតក្នុងទំហំនៃសិទ្ធិអំណាចសម្រេចរបស់ខ្លួនផងដែរ។ មុខងារនេះបង្កើតឡើងដើម្បីជម្រុញឲ្យមានគុណភាពនៃការសិក្សា និងវាយតម្លៃកម្ចី និងពង្រឹងគុណភាពនៃការផ្តល់កម្ចីផងដែរ។ លើសពីនេះ គណៈកម្មការឥណទានមានតួនាទី និងការទទួលខុសត្រូវក្នុងការកែតម្រូវ និងពង្រឹងប្រសិទ្ធភាពនៃការវាយតម្លៃកម្ចី និងការបញ្ចេញកម្ចី។ តួនាទីទាំងអស់របស់គណៈកម្មការឥណទានគឺបង្កើតឡើងដើម្បីរក្សាសុវត្ថិភាព និងត្រួតពិនិត្យពីហានិភ័យក្នុងការផ្តល់កម្ចី ហើយគណៈកម្មការនេះមានសមាជិកចំនួន៤រូបសំខាន់ៗ ដែលជ្រើសរើសយកចេញពីផ្នែកផ្សេងៗក្នុងគ្រឹះស្ថាន រួមបញ្ចូលទាំងមុខងារឯករាជ្យ០១រូបផងដែរ។ សមាជិកនៃគណៈកម្មការឥណទានមានបង្ហាញដូចខាងក្រោម៖

1. **អគ្គនាយក** **ជាប្រធានគណៈកម្មការ**
2. **នាយកប្រតិបត្តិការ** **ជាសមាជិក**
3. **ប្រធានហិរញ្ញវត្ថុ** **ជាសមាជិក**
4. **ទីប្រឹក្សាឥណទាន** **ជាសមាជិក**

**តួនាទី និង ការទទួលខុសត្រូវរបស់គណៈកម្មការឥណទានមានដូចតទៅ៖**

- ត្រួតពិនិត្យឡើងវិញនូវទម្រង់បែបបទឥណទាន ប្រវត្តិអាជីវកម្ម លំហូរសាច់ប្រាក់ និងគោលបំណងកម្ចី
- ពិនិត្យ និងអនុម័តកម្ចីដែលស្ថិតនៅក្នុងសិទ្ធិអំណាចនៃការអនុម័តកម្ចីរបស់ខ្លួន
- ធានាថាគោលនយោបាយឥណទានត្រូវបានអនុវត្តពេញលេញដោយបុគ្គលិកទាំងអស់
- ចុះត្រួតពិនិត្យអតិថិជនដល់ទីកន្លែង
- ផ្តល់យោបល់ចំពោះការសិក្សា និងវាយតម្លៃកម្ចី និងការវាយតម្លៃទ្រព្យបញ្ចាំ ព្រមទាំងការងារបច្ចេកទេសដទៃទៀត
- ផ្តល់យោបល់ចំពោះការធ្វើវិសោធនកម្មលើគោលនយោបាយឥណទាន
- អនុម័តកម្ចីដែលមានទំហំទឹកប្រាក់លើសពី $១០,០០០ ឡើងទៅ
- រាយការណ៍ជូនក្រុមប្រឹក្សាភិបាល។

### ដំណើរការសិក្សា និងវាយតម្លៃឥណទាន

ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងប្រសិទ្ធភាពនៃការសិក្សា និងវាយតម្លៃកម្ចី គោលនយោបាយឥណទានបានចែងលំអិតអំពីវិធីសាស្ត្រច្បាស់លាស់ក្នុងការសិក្សានិងវាយតម្លៃកម្ចីមុនពេលឈានដល់ការសម្រេចចិត្តពីបណ្ដាអ្នកជាប់ពាក់ព័ន្ធទាំងអស់ដែលមានសិទ្ធិអំណាចសម្រេចកម្ចី។ **ទ្រព្យខ្ញុំ** បានបង្កើតដំណើរការចំនួន១០ជំហាន ដែលតម្រូវឲ្យមន្ត្រីឥណទាន ប្រធានឥណទាន នាយកសាខាអនុវត្តតាមឲ្យបានហ្មត់ចត់ បន្ទាប់ពីទទួលបានសំណើសុំកម្ចីពីអតិថិជន។

### សិទ្ធិអំណាចអនុម័តកម្ចី

គោលនយោបាយឥណទាន គឺបានកំណត់សិទ្ធិអំណាចនៃការអនុម័តឥណទាន របស់អ្នកដែលមានសិទ្ធិនៅក្នុងការសម្រេចចិត្តចំពោះទំហំកម្ចីច្បាស់លាស់ក្នុង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក។ ចំពោះអ្នកដែលមានសិទ្ធិអំណាចអនុម័តកម្ចីរួមមានៈ ប្រធានឥណទាន នាយកសាខា នាយកប្រតិបត្តិការ អគ្គនាយក និងគណៈកម្មការឥណទាន។ គោលការណ៍នេះគឺបានបែងចែកតួនាទី និងផ្ដល់អំណាចនៃការអនុម័តកម្ចីចំពោះបុគ្គលសំខាន់ៗ ដែលជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការ និងធានាគុណភាពឥណទានផងដែរ។ ការបែងចែកសិទ្ធិអំណាចនៃការអនុម័តកម្ចី គឺជាវិធីសាស្ត្របង្កើនគុណភាពបញ្ចេញកម្ចី ក៏ដូចជាវិធីសាស្ត្រត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធនឹងការបញ្ចេញកម្ចីផងដែរ។

### ការត្រួតពិនិត្យឥណទាន

ការត្រួតពិនិត្យកម្ចីពីបណ្ដាអ្នកគ្រប់គ្រងតាមលំដាប់លំដោយ គឺជាវិធីសាស្ត្រមួយដែលត្រូវបានអនុវត្តដោយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ហើយការត្រួតពិនិត្យនេះ គឺតម្រូវឲ្យអ្នកគ្រប់គ្រងដែលជាប់ពាក់ព័ន្ធប្រតិបត្តិការបង្កើនសកម្មភាពត្រួតពិនិត្យជាប្រចាំចំពោះកម្ចីដែលបានបញ្ចេញរួចហើយ នៅក្នុងគោលបំណងការពារ និងស្វែងរកការកែបន្លំ និងការឃុបឃិតគ្នាក្នុងការផ្ដល់កម្ចី ដែលប្រព្រឹត្តិដោយបុគ្គលណាម្នាក់ដែលបានជាប់ពាក់ព័ន្ធនឹងការវាយតម្លៃ និងបញ្ចេញកម្ចី។ អ្នកដែលមានតួនាទីក្នុងការត្រួតពិនិត្យកម្ចីរួមមានៈ នាយកប្រតិបត្តិការ នាយកសាខា និងប្រធានឥណទាន។ ក្នុងគោលនយោបាយឥណទាននេះ ការត្រួតពិនិត្យកម្ចី គឺជាការផ្ដោតសំខាន់ទៅលើការពិនិត្យសំណុំឯកសារ និងចុះត្រួតពិនិត្យអតិថិជនដល់ទីកន្លែង។

### ដែនកំណត់នៃកម្ចី

ដើម្បីជាផ្នែកមួយ នៃការគ្រប់គ្រងហានិភ័យឥណទាន ការកាត់បន្ថយទំហំកម្ចី និងការកំណត់ទំហំកម្ចី ជាវិធានការមួយដែលគ្រឹះស្ថានបានធ្វើឡើង ក្នុងការកាត់បន្ថយនូវហានិភ័យនៃការផ្ដល់កម្ចីផងដែរ ហើយកម្មវត្ថុនៃការកាត់បន្ថយទំហំកម្ចី ធ្វើឡើងដើម្បីបង្កើនចំនួនអតិថិជន និង សុខភាពនៃកម្ចីផងដែរ។ វិធីសាស្ត្រនេះអាចជួយបំបែកហានិភ័យនៅក្នុងករណីកើតមានកម្ចីយឺតយ៉ាវច្រើន ព្រោះវាអាចជួយការពារកម្ចីរបស់យើងកុំឲ្យមានហានិភ័យខ្ពស់ពេក។ ដូច្នេះហើយ ទើបគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ពិចារណាក្នុងការផ្ដល់កម្ចីខ្នាតតូចជូនអតិថិជនរបស់ខ្លួនដើម្បីកាត់បន្ថយនូវហានិភ័យចំពោះប្រតិបត្តិការឥណទាន។

### ការកាត់បន្ថយហានិភ័យឥណទាន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ផ្ដោតលើកត្តាពីរយ៉ាងសំខាន់ៗនៅក្នុងការកាត់បន្ថយហានិភ័យឥណទានរបស់ខ្លួន ហើយកត្តាទាំង២ ដែលបានចូលរួមចំណែកយ៉ាងសំខាន់ នៅក្នុងការកាត់បន្ថយហានិភ័យឥណទានរួមមានៈ អ្នកធានាកម្ចី និងទ្រព្យដាក់បញ្ចាំ។ ចំពោះការពិពណ៌នាអំពីកត្តាសំខាន់ទាំង២មានបង្ហាញដូចតទៅៈ

- **អ្នកធានាកម្ចី:** អ្នកធានាកម្ចីជាកត្តាដ៏សំខាន់មួយក្នុងចំណោមកត្តាសំខាន់ៗផ្សេងៗទៀតដែលបានចូលរួមរក្សាសុវត្ថិភាពនៃកម្ចីរបស់យើង ហើយនៅក្នុងការអនុវត្តជាក់ស្តែងគ្រប់អតិថិជនដែលបានអនុម័ត គឺមានអ្នកធានាម្នាក់ ឬពីរនាក់ដែលយល់ព្រមផ្តិតស្នាមមេដៃធានានៅលើកិច្ចសន្យាធានាសងប្រាក់។ ការរៀបចំកិច្ចសន្យាសងប្រាក់ គឺធ្វើឡើងដើម្បីធានាថា អ្នកធានាយល់ព្រមធានាសងប្រាក់ជំនួសទាំងប្រាក់ដើម និងការប្រាក់ នៅពេលដែលអ្នកខ្ចីគ្មានលទ្ធភាពសងប្រាក់ជូនដល់គ្រឹះស្ថានវិញ ស្របទៅតាមកិច្ចសន្យាចងការប្រាក់ ឬតារាងសងប្រាក់ដែលគ្រឹះស្ថានបានចេញជូន។
- **ទ្រព្យដាក់បញ្ចាំ:** ដើម្បីកាត់បន្ថយហានិភ័យឥណទាន គ្រប់អតិថិជនទាំងអស់ដែលចង់បានកម្ចីពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ត្រូវបានតម្រូវឲ្យដាក់ទ្រព្យបញ្ចាំដែលជាផ្នែកមួយនៅក្នុងការរក្សាសុវត្ថិភាពកម្ចី។ ទ្រព្យបញ្ចាំ ១០០% ដែលបានដាក់បញ្ចាំដោយអតិថិជន គឺធ្វើឡើងគ្រប់ប្រភេទផលិត ផលទាំងអស់របស់គ្រឹះស្ថាន ហើយទ្រព្យដាក់បញ្ចាំមានសុពលភាព ដែលគ្រឹះស្ថានយល់ព្រមទទួលយកនោះ គឺមានច្រើនប្រភេទផ្អែកទៅលើ ផលិតផលឥណទាននីមួយៗរបស់គ្រឹះស្ថាន។ ជាទូទៅ ទ្រព្យបញ្ចាំសំខាន់ៗដែលគ្រឹះស្ថានបានយល់ព្រមទទួលយករួមមានៈប័ណ្ណសម្គាល់យានយន្តសម្រាប់ម៉ូតូ រថយន្ត និងឡានដឹកទំនិញព្រមទាំងប្លង់ដី។ ទ្រព្យដាក់បញ្ចាំទាំងអស់ត្រូវមានភាពស្របច្បាប់ត្រឹមត្រូវ និងមានតម្លៃតាមទីផ្សារជាក់ស្តែង ដែលត្រូវបានសិក្សា និងវាយតម្លៃយ៉ាងត្រឹមត្រូវពីបុគ្គលិកដែលមានជំនាញរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទ្រព្យខ្ញុំ ម.ក។ លើសពីនេះទៀត ការធ្វើផលធៀបរវាងកម្ចី និងតម្លៃទ្រព្យបញ្ចាំ គឺជាចំណុចដ៏សំខាន់ពាក់ព័ន្ធទៅនឹងទ្រព្យបញ្ចាំដែលនឹងត្រូវបានពិចារណា យ៉ាងល្អិតល្អន់ មុនពេលសម្រេចផ្តល់កម្ចី។
- **ឯកសារកម្ចី:** គ្រប់ឯកសារកម្ចីទាំងអស់ត្រូវបានរក្សាទុកដោយប្រុងប្រយ័ត្ន ដោយមន្ត្រីរដ្ឋបាលតាមសាខានីមួយៗ ហើយគ្រឹះស្ថានបានអនុវត្តជម្រើសពីរបែប ក្នុងការរក្សាទុករួមមានៈ រក្សាទុកឯកសាររឹងមួយផ្នែក និងឯកសារទន់មួយផ្នែកផងដែរ។ ចំពោះឯកសាររឹងត្រូវបានរក្សាទុកក្នុងទូសុវត្ថិភាព និងគ្រប់គ្រងរក្សាទុកជាឯកសារកាលប្បវត្តិផងដែរ។ ចំណែកឯកសារទន់ត្រូវបានរក្សាទុកក្នុងទិន្នន័យកុំព្យូទ័រ តាមរយៈការស្កេនគ្រប់ឯកសារដែលពាក់ព័ន្ធបានទាន់ពេលវេលា។ ក្នុងនោះដែរ ទាំងឯកសាររឹង និងទន់ត្រូវបានគ្រប់គ្រងដោយប្រព័ន្ធកុំព្យូទ័រ ដែលធ្វើឲ្យមន្ត្រីរដ្ឋបាលងាយស្រួលនៅក្នុងការតាមដាន និង ទាញយកទិន្នន័យត្រឡប់មកវិញបានតាមតម្រូវការ។ ឯកសារកម្ចីគឺត្រូវបានទទួលស្គាល់ថា ជាប្រភេទឯកសារសំខាន់បំផុតដែលអាចផ្តល់ភស្តុតាង និងបញ្ជាក់ពីភាពត្រឹមត្រូវថា អតិថិជនបានខ្ចីប្រាក់ពីគ្រឹះស្ថាន ហើយឯកសារទាំងនេះក៏ធ្វើឡើងដើម្បីធ្វើឲ្យស្របតាមច្បាប់នៃកិច្ចព្រមព្រៀង រវាងភាគីទាំងពីរផងដែរ។
- **ប្រព័ន្ធគ្រប់គ្រងព័ត៌មាន:** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បាននិងកំពុងប្រើប្រាស់ប្រព័ន្ធដែលមានឈ្មោះថា MB9 ដែលជាប្រព័ន្ធព័ត៌មានវិទ្យាដែលមានតួនាទីគ្រប់គ្រង និងកត់ត្រាប្រតិបត្តិការឥណទាន។ ហូតមកដល់បច្ចុប្បន្ននេះ យើងជឿជាក់ថា ប្រព័ន្ធ MB9 គឺជាប្រព័ន្ធមួយដែលផ្តល់ទំនុកចិត្ត និងព័ត៌មានដ៏ត្រឹមត្រូវក្នុងការគ្រប់គ្រងកម្ចី។ ប្រព័ន្ធនេះអាចជួយផលិតនូវទិន្នន័យបានច្រើនទៅតាមតម្រូវការរបស់យើង ហើយជាប្រព័ន្ធដែលអាចបញ្ចូលទិន្នន័យចម្រុះ រវាងព័ត៌មានកម្ចីនិងប្រព័ន្ធគណនេយ្យដែលអាចមានសមត្ថភាព ក្នុងការជម្រុញប្រសិទ្ធភាពនៃការងារបានលឿនផងដែរ។ MB9 គឺជាប្រព័ន្ធស្នូលមួយ ដែលអាចជួយពង្រឹងការគ្រប់គ្រងហានិភ័យឥណទាន តាមរយៈសមត្ថភាពនៅក្នុងការតាមដានកំណត់ត្រាឥណទាន ជាពិសេស គឺរបាយការណ៍យឺតយ៉ាវប្រចាំថ្ងៃ និងរបាយការណ៍សំខាន់ដទៃទៀត ស្របពេលជាមួយគ្នានេះដែរ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បានចាត់តាំងបុគ្គលសំខាន់ៗ ដែលមានបទពិសោធន៍ជាច្រើនឆ្នាំ ក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ឲ្យទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធ MB9 នេះផងដែរ។

- **គោលការណ៍ណែនាំក្នុងការផ្តល់កម្ចីៈ** គ្រឹះ ស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក គឺជាសមា ជិកនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) គោលការណ៍ណែនាំក្នុងការផ្តល់កម្ចី គឺត្រូវបានអនុម័តដោយ CMA ហើយត្រូវបានដាក់ចេញឲ្យសមាជិកទាំងអស់អនុវត្ត។ ដើម្បីគ្រប់គ្រងហានិភ័យក្នុងការផ្តល់កម្ចីគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក តែងតែបានអនុ លោមយ៉ាងខ្ជាប់ខ្ជួនទៅតាមគោលការណ៍នៃការផ្តល់កម្ចីនេះហើយ ឧបករណ៍នេះត្រូវបាន ប្រើប្រាស់ដូចគ្នានឹង លទ្ធផលប្រតិបត្តិការឥណទាន ក៏ដូចជាការត្រួតពិនិត្យហានិភ័យក្នុងការផ្តល់កម្ចីផងដែរ។ ដូច្នេះ យើងយកចិត្តទុកដាក់ចំពោះកម្ចី ធៀបទៅនឹងប្រាក់ចំណូល វិធានចំពោះការផ្តល់កម្ចីត្រួតជាន់គ្នា បំរែបំរួលកម្ចីចំពោះម្ចាស់បំណុល ហើយនិងសន្ទស្សន៍ហានិភ័យកម្ចី។ ឧបករណ៍ទាំងនេះនឹងជួយក្រើនរំលឹកដល់ **ទ្រព្យខ្ញុំ** ឲ្យមានការប្រុងប្រយ័ត្ន ចំពោះការសម្រេចចិត្តក្នុងការផ្តល់កម្ចីដល់អតិថិជនផងដែរ។
- **ការឆែកCBC :** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្របច្បាប់ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងជាសមាជិករបស់**ក្រុមហ៊ុន ក្រេឌីត ប្យ៉ូរ ខេមបូឌា** (CBC) ផងដែរ។ ដើម្បីការពារហានិភ័យ ដែលអាចកើតមានឡើងនៅក្នុងការផ្តល់កម្ចី អ្នកដាក់ពាក្យស្នើសុំកម្ចីទាំងអស់ត្រូវបានស្នើសុំឲ្យចុះកិច្ចព្រមព្រៀងចែករំលែកព័ត៌មានឥណទាន ដែលអាចអនុញ្ញាតឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យ ខ្ញុំ ម.ក មានសិទ្ធិឆែកCBCដើម្បីប្រមូលព័ត៌មានបន្ថែមពាក់ព័ន្ធទៅនឹងប្រវត្តិរបស់អ្នកខ្ចីប្រាក់ផងដែរ។ ការធ្វើបែបនេះគឺអាចជួយដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ឲ្យមានភាពងាយស្រួលក្នុងសម្រេចថាតើ គួរផ្តល់កម្ចីជូនដល់អតិថិជន ឬអត់? ចំពោះការធ្វើប្រតិបត្តិការបច្ចុប្បន្ន យើងបានអនុលោមពេញលេញស្របតាមលក្ខខណ្ឌដែលបានតម្រូវឲ្យឆែក CBC គ្រប់អតិថិជនទាំងអស់មុនពេលផ្តល់កម្ចី។ ប្រព័ន្ធ CBC បានចូលរួមចំណែកយ៉ាងសំខាន់ នៅក្នុងការគ្រប់គ្រងហានិភ័យឥណទាន ក៏ដូចជាការធានានូវគុណភាពកម្ចីនៅក្នុងគ្រឹះស្ថានទាំងស្រុងផងដែរ។

## ១៥. អភិបាលកិច្ច

### ក្រុមប្រឹក្សាភិបាល

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក មានក្រុមប្រឹក្សាភិបាលដែលខ្លាំងក្លា ហើយដើរតួនាទីយ៉ាងសំខាន់ ដើម្បីធានាថាគ្រឹះស្ថានប្រកបសកម្មភាពមីក្រូហិរញ្ញវត្ថុដោយប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ និងគោរពតាមបទដ្ឋាននៃបទប្បញ្ញត្តិនានាដែរ។ ក្រុមប្រឹក្សាភិបាលបានចូលរួមចំណែកយ៉ាងច្រើនក្នុងការសម្រេចចិត្តពីយុទ្ធសាស្រ្ត ត្រួតពិនិត្យគោលនយោបាយ និងបង្កើនអភិបាលកិច្ចអាជីវកម្ម។ នៅក្នុងឆ្នាំ២០២០ ក្រុមប្រឹក្សាភិបាលបានបើកកិច្ចប្រជុំសាមញ្ញយ៉ាងទៀងទាត់ ស្របតាមកាលវិភាគប្រចាំឆ្នាំដើម្បីពិភាក្សាអំពីប្រតិបត្តិការរបស់គ្រឹះស្ថាន ស្វែងរកនូវជម្រើសនៅក្នុងការដោះស្រាយបញ្ហាប្រឈម និងកំណត់យុទ្ធសាស្រ្តសួល សម្រាប់ប្រតិបត្តិការរយៈពេលវែងរបស់គ្រឹះស្ថានផងដែរ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក មានក្រុមប្រឹក្សាភិបាលដែលមានសមត្ថភាពខ្លាំង និងបទពិសោធន៍រយៈពេលជាច្រើនឆ្នាំ ដែលមានចំណេះដឹងទូលំទូលាយពាក់ព័ន្ធទៅនឹងការដឹកនាំសាជីវកម្ម ជាពិសេសវិស័យហិរញ្ញវត្ថុ។ អភិបាលទាំងអស់ គឺជាបុគ្គលដែលមានកម្រិតវប្បធម៌ខ្ពង់ខ្ពស់ និងជាបុគ្គលដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងសង្គម ដែលទទួលស្គាល់ដោយក្រុមហ៊ុនអាជីវកម្មក្នុងប្រទេសកម្ពុជា។

ក្រុមប្រឹក្សាភិបាលមានសមាសភាពចំនួន០៣រូប ដូចខាងក្រោម៖

1. លោក **ឡែម ចាន់សំរេច** ប្រធានក្រុមប្រឹក្សាភិបាល
2. លោក **លឹម សុជាតិ** អភិបាល
3. លោក **ណា សុធី** អភិបាល

តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលរួមមានៈ

- បង្កើតយុទ្ធសាស្រ្ត និងគោលដៅគ្រឹះស្ថាន អនុលោមទៅតាមបទប្បញ្ញត្តិរបស់គ្រឹះស្ថាន
- ផ្តល់ទិសដៅជាយុទ្ធសាស្រ្ត និងត្រួតពិនិត្យ គោលនយោបាយ និងនីតិវិធីនានា
- ត្រួតពិនិត្យលើអភិបាលកិច្ចសាជីវកម្មរបស់គ្រឹះស្ថាន
- ផ្តល់ទិសដៅជាយុទ្ធសាស្រ្តដល់ថ្នាក់គ្រប់គ្រង
- ចូលរួមចំណែកការពារ និងធានានូវនិរន្តរភាពរបស់គ្រឹះស្ថាន។

### អភិបាលឯករាជ្យ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក មានអភិបាលឯករាជ្យចំនួន០១រូប ដែលជាក្រុមប្រឹក្សាភិបាលឯករាជ្យទទួលបន្ទុកសវនកម្ម និងប្រតិបត្តិតាម ក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ។ អភិបាលឯករាជ្យដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញឲ្យមានឯករាជ្យភាព ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ក្រៅពីចំណេះដឹង និងជំនាញបច្ចេកទេសដែលមុខងារនេះមាន។ អភិបាលឯករាជ្យមានកាតព្វកិច្ចគាំទ្រឲ្យមានបទដ្ឋានកម្រិតខ្ពស់នៃសុចរិតភាព និងភាពស្មោះត្រង់ ហើយជម្រុញឲ្យមានទំនាក់ទំនងល្អ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលឯករាជ្យត្រូវអនុវត្តស្តង់ដារនៃការយកចិត្តទុកដាក់ និងជំនាញតែមួយចំពោះតួនាទីរបស់ខ្លួនក្នុងក្រុមហ៊ុន ឲ្យដូចអ្វីដែលខ្លួនបានអនុវត្តនៅកន្លែងផ្សេងដែរ។ អភិបាលឯករាជ្យរួមទាំងប្រធានក្រុមប្រឹក្សាភិបាល មានតួនាទីសម្របសម្រួលកិច្ចប្រជុំ ដើម្បីជម្រុញឲ្យសមាជិកក្រុមប្រឹក្សាភិបាលយកចិត្តទុកដាក់ ចំពោះលទ្ធផលការងាររបស់ក្រុមប្រឹក្សាភិបាល។ លើសពីនេះ អភិបាលឯករាជ្យត្រូវបានរំពឹងថា នឹងចូលរួមយ៉ាងពេញលេញនៅក្នុងនាមជាសមាជិកគណៈកម្មការនៃក្រុមប្រឹក្សាភិបាលដែលបានតែងតាំង និងទទួលតួនាទីជាប្រធានគណៈកម្មការនៅពេលមានការតែងតាំងកើតឡើង។

**ភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលឯករាជ្យមានដូចខាងក្រោម៖**

- ជួយគាំទ្រដល់ប្រធានក្រុមប្រឹក្សាភិបាល អគ្គនាយក នាយកប្រតិបត្តិ នៅក្នុងការលើកកម្ពស់គុណតម្លៃរបស់គ្រឹះស្ថាន
- ចូលរួមចំណែកអភិវឌ្ឍយុទ្ធសាស្ត្រ
- ចូលរួមប្រជុំក្រុមប្រឹក្សាភិបាលតាមការស្នើសុំរបស់គ្រឹះស្ថាន
- ទទួលបន្ទុកជាប្រធានគណៈកម្មការសវនកម្ម
- បង្កើត និង រៀបចំរចនាសម្ព័ន្ធគណៈកម្មការសវនកម្ម និងក្រុមសវនកម្មផ្ទៃក្នុង
- ពិនិត្យ និង វាយតម្លៃលំហូរការងារគណៈកម្មការសវនកម្ម យ៉ាងហោចណាស់១លើកនៅរៀងរាល់៣ឆ្នាំម្តង ឬញឹកញាប់ជាងនេះ តាមករណីចាំបាច់
- រៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំសម្រាប់គណៈកម្មការ
- ត្រួតពិនិត្យការប្រតិបត្តិចំពោះផែនការការងារ ហើយត្រួតពិនិត្យឡើងវិញនូវភាពចាំបាច់សម្រាប់ការកែប្រែណាមួយ
- រាយការណ៍ជូនក្រុមប្រឹក្សាភិបាលស្តីពីការងាររបស់គណៈកម្មការឲ្យបានទាន់ពេលវេលា និងត្រឹមត្រូវ
- ផ្តល់ឱកាសឲ្យសមាជិកទាំងអស់ទទួលបានការបណ្តុះបណ្តាលបន្ថែម
- បើកកិច្ចប្រជុំគណៈកម្មការ យ៉ាងហោចណាស់ឲ្យបាន១ឆ្នាំម្តង
- ធានាថាគណៈកម្មការនេះបានអនុវត្តមុខងារពេញលេញ អនុលោមតាមបទប្បញ្ញត្តិដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។

**គណៈកម្មការប្រតិបត្តិ**

គណៈកម្មការប្រតិបត្តិត្រូវបានបង្កើតឡើងដើម្បីតម្រង់ទិសដៅការងារ និងដឹកនាំលើការអនុវត្តគោលនយោបាយ ហើយនិងនីតិវិធីនានារបស់ថ្នាក់គ្រប់គ្រង ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ មុខងារនេះដើរតួនាទីសកម្ម និងមានអំណាចគ្រប់គ្រងលើប្រតិបត្តិការទាំងមូលរបស់គ្រឹះស្ថាន។ គណៈកម្មការនោះដើរតួនាទីជំនួសឲ្យក្រុមប្រឹក្សាភិបាលជាលក្ខណៈបណ្តោះអាសន្ន សម្រាប់រាល់ការធ្វើសេចក្តីសម្រេចលក្ខណៈបន្ទាប់ណាមួយត្រូវបានធ្វើឡើង។ ចំពោះតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការនេះរួមមានៈ

- ត្រួតពិនិត្យលើការអនុវត្តការងាររបស់គ្រឹះស្ថានទាំងស្រុង
- បង្កើតយុទ្ធសាស្ត្រ គោលនយោបាយ និងនីតិវិធីនានា
- ផ្តល់យោបល់ពាក់ព័ន្ធការអនុវត្តការងារប្រចាំថ្ងៃ
- ត្រួតពិនិត្យលទ្ធផលប្រតិបត្តិការ
- កំណត់អត្តសញ្ញាណ សិក្សា និងវាយតម្លៃហានិភ័យ
- ត្រួតពិនិត្យ និងវាយតម្លៃអំពីការរីកចម្រើននៃយុទ្ធសាស្ត្រ គោលដៅ និងគំនិតផ្តួចផ្តើម
- គ្រប់គ្រង និងបង្ហាញលទ្ធផលប្រតិបត្តិការប្រចាំឆ្នាំជូនក្រុមប្រឹក្សាភិបាល។

សមាសភាពនៃគណៈកម្មការប្រតិបត្តិត្រូវបង្កើតឡើងដោយមានមុខងារដូចជាៈ អគ្គនាយក នាយកប្រតិបត្តិការ ប្រធានហិរញ្ញវត្ថុ និងនាយកសាខា។ ព័ត៌មានលំអិតអំពីសមាសភាពគណៈកម្មការប្រតិបត្តិមានដូចតទៅៈ

- លោក **ដាន់ ឈឹម** **ប្រធានគណៈកម្មការ**
- លោក **អៀម វាសនា** សមាជិក
- លោក **សួន សីហា** សមាជិក
- លោក **សោម ហ៊ុយ** សមាជិក
- លោក **ឈួក សុជាតិ** សមាជិក

## គណៈកម្មការគ្រប់គ្រងសាខា

គណៈកម្មការគ្រប់គ្រងសាខាត្រូវបានបង្កើតឡើងនៅតាមសាខានីមួយៗ ដើម្បីទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់ គ្រងប្រតិបត្តិការរួមប្រចាំសាខា ហើយគណៈកម្មការនេះ ដើរតួនាទីជាបណ្តោះអាសន្នជំនួសឲ្យគណៈកម្មការប្រតិបត្តិ និងអគ្គនាយកចំពោះរាល់សេចក្តីសម្រេចណាមួយក្នុងកម្រិតសាខា ប៉ុន្តែចាំបាច់ត្រូវតែរាយការណ៍ជាមុន ជូនគណៈកម្មការប្រតិបត្តិ និងអគ្គនាយក។ គណៈកម្មការនេះមានតួនាទីត្រួតពិនិត្យប្រតិបត្តិការតាមសាខា អនុវត្តគោលនយោបាយ ធ្វើផែនការ និងគ្រប់គ្រងហានិភ័យ។ សមាសភាពគណៈកម្មការគ្រប់គ្រងសាខាគឺបានយកចេញពីរចនាសម្ព័ន្ធថ្នាក់សាខាដែលមានស្រាប់ដូចជា នាយកសាខា ប្រធានឥណទាន គណនេយ្យករ និងបុគ្គលិកសំខាន់ៗតាមសាខានីមួយៗ។ ជារួម នាយកសាខា គឺជាប្រធានគណៈកម្មការ ហើយគណៈកម្មការនេះមានសមាជិកចាប់ពី៣ដល់៥រូប អាស្រ័យទៅលើទំហំនៃសាខានីមួយៗ។

**តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងសាខាមានបង្ហាញដូចតទៅៈ**

- ប្រមូលព័ត៌មាននានាដែលជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការសាខា
- ចូលរួមបង្កើតយុទ្ធសាស្រ្ត
- ជួយគាំទ្រប្រតិបត្តិការសាខាដើម្បីជានាឲ្យប្រតិបត្តិការសាខាមានគុណភាព និងប្រសិទ្ធភាព
- បង្កើនសកម្មភាពត្រួតពិនិត្យប្រតិបត្តិការសាខា
- ចែកចាយព័ត៌មាននានាជូនបុគ្គលិកតាមសាខា។

## ១៦. សាច់រឿងអតិថិជនជោគជ័យ



**លោក ឡេង វិសាល និងអ្នកស្រី សាយ លក្ខិណា**

លោក ឡេង វិសាល អាយុ ៣១ និង អ្នកស្រី សាយ លក្ខិណា អាយុ ៣១ ឆ្នាំ សព្វថ្ងៃកំពុងរស់នៅក្នុងភូមិវត្តរំដួល សង្កាត់ចំការសំរោង ខេត្តបាត់ដំបង ហើយពួកគេជាប្តីប្រពន្ធនឹងគ្នាដោយមានកូនចំនួន២នាក់ក្នុងគ្រួសារ។ ពួកគេបានប្រកបមុខរបរជាអ្នកលក់សំលៀកបំពាក់ ចានឆ្នាំង និងសម្ភារៈផ្ទះបាយ តាំងពីឆ្នាំ២០១៤។ ពួកគេបានប្រកបមុខរបរនេះជាលើកដំបូងតាមរយៈទូរស័ព្ទដៃ ដោយដឹកតាមម៉ូតូ។ ចាប់តាំងពីចាប់ផ្តើមប្រកបរបរនេះរួច អាជីវកម្មរបស់ពួកគេបានរីកចម្រើនច្រើន ហើយពួកគេត្រូវការដើមទុនបន្ថែម និងមធ្យោបាយដឹកជញ្ជូនផងដែរ។

លោក វិសាល និង អ្នកស្រី លក្ខិណា បានប្រើប្រាស់ប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ចាប់តាំងពីឆ្នាំ២០១៨។ ចំពោះកម្ចីលើកទី១ ពួកគេបានខ្ចីប្រាក់ចំនួន ៧,០០០ ដុល្លារអាមេរិកសម្រាប់ធ្វើជាដើមទុន និងទិញរថយន្តដើម្បីជម្រុញការលក់របស់ពួកគេ។ ក្រោយពីអាជីវកម្មមានដំណើរការល្អ ពួកគេបានខ្ចីប្រាក់នៅវគ្គទី២ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ចំនួន១២,០០០ដុល្លារអាមេរិក។ កម្ចីវគ្គទី២នេះគឺប្រើប្រាស់សម្រាប់ធ្វើជាដើមទុនបន្ថែមរបស់ពួកគេផងដែរ លោក វិសាល និងអ្នកស្រី លក្ខិណា គឺជាអតិថិជនល្អដែលបង់សងប្រាក់បានល្អ និងទៀងទាត់ ហើយពួកគេមានលទ្ធភាពគ្រប់គ្រាន់ក្នុងការសងប្រាក់ជូនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ។

លោក វិសាល បានរៀបរាប់ថា « ចាប់តាំងពីខ្ញុំបានប្រើប្រាស់ប្រាក់កម្ចីពី ទ្រព្យខ្ញុំ អាជីវកម្មរបស់ខ្ញុំមានដំណើរការល្អ ហើយស្ថានភាពគ្រួសាររបស់ខ្ញុំក៏កាន់តែធូរធារផងដែរ។ បច្ចុប្បន្ននេះ ខ្ញុំនៅសល់សមតុល្យប្រាក់ដើមចំនួន ១០,០០០ ដុល្លារអាមេរិក ហើយខ្ញុំពិតជាមានការជឿជាក់ជាមួយអាជីវកម្ម និងប្រាក់ចំណូលរបស់ខ្ញុំ » ។

ជាចុងក្រោយ ខ្ញុំពិតជាសប្បាយចិត្តដែលជីវិតខ្ញុំ និងគ្រួសាររបស់ខ្ញុំមានការផ្លាស់ប្តូរបែបវិជ្ជមាន និងរីកចម្រើនលូតលាស់បែបនេះ។ ខ្ញុំក៏សូមអរគុណដល់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ដែលបានផ្តល់សេវាកម្មល្អ និងទំនាក់ទំនងល្អ ជាទីទុកចិត្តចំពោះក្រុមគ្រួសាររបស់ខ្ញុំ ហើយខ្ញុំនឹងបន្តគាំទ្រ និងប្រើប្រាស់ផលិតផល និងសេវាកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បន្តទៅមុខទៀត។



**លោក អោត ស៊ី និង អ្នកស្រី ញោក យួន**

លោក អោត ស៊ី អាយុ៥៥ និងអ្នកស្រី ញោក យួន អាយុ ៤៧ ពួកគេជាប្តីប្រពន្ធដែលកំពុងរស់នៅភូមិកូនក្រោល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ក្រុមគ្រួសារពួកគេទាំងពីរមានកូនចំនួន៦នាក់ ហើយក្នុងនោះកូនប្រុសចំនួន០៥នាក់ ហើយពួកគេប្រកបមុខរបរជាកសិករចាប់តាំងពីឆ្នាំ១៩៧៩។

លោក ស៊ី និងអ្នកស្រី យួន ចាប់ផ្តើមខ្ចីប្រាក់ពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ចាប់ពីឆ្នាំ២០១៦។ ចំពោះប្រាក់កម្ចីវគ្គទី១ ពួកគេទាំងពីរបានខ្ចីប្រាក់ចំនួន ២០,០០០ ដុល្លារអាមេរិក ដើម្បីយកទៅទិញត្រាក់ទ័រមួយគ្រឿង សម្រាប់ប្រកបការងារកសិកម្មលើដីចំការស្វាយ និងដំឡូងមី។ ពួកគេអាចទទួលបានកម្ចីនេះ តាមរយៈមន្ត្រីឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ដែលបានចុះផ្សព្វផ្សាយអំពីផលិតផល និងសេវាកម្ម។ ក្រោយពីបានបង់សងរួចចំពោះវគ្គទី១ ពួកគេបានសម្រេចចិត្តខ្ចីប្រាក់វគ្គទី២បន្តពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ដើម្បីទិញត្រាក់ទ័រមួយគ្រឿងទៀត នៅឆ្នាំ២០២០។ សម្រាប់វគ្គទី២នេះ ពួកគេបានខ្ចីប្រាក់ចំនួន ១៣,០០០ ដុល្លារអាមេរិកហើយបច្ចុប្បន្ននេះពួកគេមានដីស្រែចំនួន៣ហិកតា និងចំការស្វាយ និងដំឡូងមីចំនួន១៥ហិកតាផងដែរ។ លោក អោត ស៊ី និងអ្នកស្រី ញោក យួន គឺជាអតិថិជនដែលមានសក្តានុពល ហើយមានលទ្ធភាពខ្ពស់ក្នុងការបង់សងត្រឡប់មកវិញបានទាន់ពេលវេលា។

លោក អោត ស៊ី បានរៀបរាប់ថា « បច្ចុប្បន្ននេះ សមតុល្យប្រាក់ដើមរបស់ខ្ញុំ គឺនៅសល់ចំនួន ១២,៣៧០ ដុល្លារអាមេរិក ហើយក្រោយពីខ្ញុំបានទិញត្រាក់ទ័រមួយទៀត វាបានផ្ដល់ភាពងាយស្រួលដល់ខ្ញុំខ្លាំងណាស់។ ម្យ៉ាងវិញទៀត ក្នុងរាល់ដីរបស់ខ្ញុំរួចរាល់ ខ្ញុំអាចឆ្លៀតស៊ីឈ្នួលភ្ជួររាស់ដីឲ្យអ្នកភូមិដើម្បីទទួលបានប្រាក់ចំណូលបន្ថែមទៀត ដែលនេះគឺជាឱកាសល្អសម្រាប់ក្រុមគ្រួសាររបស់ខ្ញុំដែលអាចរកប្រភពប្រាក់ចំណូលបន្ថែមបាន។ ខ្ញុំជឿជាក់ថា ខ្ញុំពិតជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់សងត្រឡប់វិញ ដោយសារខ្ញុំមានប្រភពប្រាក់ចំណូលបន្ថែមពីចំការស្វាយ និងចំការដំឡូងមីរបស់ខ្ញុំ » ។ លោក ស៊ី បានរៀបរាប់បន្តទៀតថា « ខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំមានការសប្បាយចិត្តយ៉ាងខ្លាំងចំពោះការរីកចម្រើនរបស់គ្រួសារខ្ញុំ ហើយសូមអរគុណដល់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ដែលបានផ្ដល់ឱកាសដល់រូបខ្ញុំឲ្យទទួលបានកម្ចីសម្រាប់ទិញត្រាក់ទ័រនេះ។ ខ្ញុំសន្យាថានឹងបន្តប្រើប្រាស់ប្រាក់កម្ចីពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ហើយសូមជូនពរឲ្យគ្រឹះស្ថានទទួលបានជោគជ័យបន្តទៅមុខទៀតជានិរន្តរ៍» ។



**លោក ថាវ សាគូរី និង អ្នកស្រី សៀត ស្មើ**

លោក ថាវ សាគូរី អាយុ ៣០ឆ្នាំ និងអ្នកស្រី សៀត ស្មើ អាយុ ២៨ឆ្នាំ ពួកគេជាប្ដីប្រពន្ធនឹងគ្នា សព្វថ្ងៃរស់នៅភូមិកន្ទួយជូន ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ ក្រុមគ្រួសាររបស់ពួកគេមានកូនចំនួន ដោយក្នុងនោះកូនប្រុស ១នាក់ និង ស្រី១នាក់។

ក្រោយពីរៀបការរួច ពួកគេបានផ្លាស់ប្ដូរទៅរស់នៅក្នុងក្រុងសំរោង ខេត្តឧត្តរមានជ័យ។ នៅក្នុងអំឡុងពេលនោះដែរ ពួកគេគ្មានមុខរបរ និងប្រាក់ចំណូលនោះទេ ហើយបាបសម្រេចចិត្តរស់នៅជាមួយម្ដាយមីង ហើយបន្ទាប់មកពួកគេបានចាប់ផ្ដើមធ្វើការងារជាកម្មករ។ ក្រោយមក លោក សាគូរី បានចូលបម្រើការងារជាយោធា ហើយបានផ្លាស់ប្ដូរទៅរស់នៅស្រុកកំណើតវិញ។ បន្ទាប់មកទៀតនោះ ក្រុមគ្រួសាររបស់ពួកគេបានប្រែប្រួលខ្លាំង ដោយសារតែមានប្រាក់ខែពីការបម្រើការងារជាយោធា។

លោក សាគូរី និងអ្នកស្រី រស្មី មិនធ្លាប់ខ្ចីប្រាក់ពីមុនមកនោះទេ ពួកគេបានចាប់ផ្តើមខ្ចីប្រាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ដែលវគ្គទី១មានទំហំទឹកប្រាក់ចំនួន៥លានរៀល ដើម្បីយកទៅប្រកបមុខរបរលក់ដូរក្នុងភូមិ ដោយក្នុងនោះពួកគេបានសម្រេចចិត្តបើកហាងលក់គ្រឿងទេស។ តាមរយៈកម្ចីដែលគ្រឹះស្ថានបានផ្តល់ជូន ក្រុមគ្រួសាររបស់ពួកគេបានរីកចម្រើនជាងមុន ដោយសារពួកគេមានប្រាក់ចំណូលបន្ថែមសម្រាប់គ្រួសាររបស់ពួកគេ។ ក្រោយពីបានបង់សងរួចវគ្គទី១ នៅក្នុងឆ្នាំ២០២០ ពួកគេបានសម្រេចចិត្តខ្ចីប្រាក់លើកទី២ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ចំនួន៥,០០០ដុល្លារអាមេរិក ដើម្បីពង្រីកអាជីវកម្មបន្ថែមទៀត និងជួលដីធ្វើចំការដំឡូងមីផងដែរ។ តាមរយៈការសង្កេតមើលស្ថានភាពជាក់ស្តែង ជីវភាពរបស់ លោក សាគូរី និងអ្នកស្រី រស្មី មានកម្រិតជីវភាពធូរធាជារឿយៗ ចាប់តាំងពីបានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក។ បច្ចុប្បន្ននេះ ពួកគេគឺជាអតិថិជនម្នាក់ដែលមានលទ្ធភាពខ្ពស់ក្នុងការសងប្រាក់ត្រឡប់វិញ។

លោក សាគូរី បានរៀបរាប់ថា « ខ្ញុំសូមអរគុណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ដែលបានជឿជាក់ ហើយផ្តល់កម្ចីដល់រូបខ្ញុំ ហើយដោយសារតែប្រាក់កម្ចីនេះ ទើបធ្វើឲ្យក្រុមគ្រួសាររបស់ខ្ញុំមានប្រាក់ចំណូលល្អដូចសព្វថ្ងៃនេះ។ បើគ្មានប្រាក់កម្ចីពី ទ្រព្យខ្ញុំ នោះទេ គ្រួសារខ្ញុំក៏មិនអាចមានជីវភាពដូចសព្វថ្ងៃនេះដែរ ហើយខ្ញុំក៏សូមអរគុណជាថ្មីម្តងទៀតដល់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ដែលបានផ្តល់កម្ចីនេះ ដែលធ្វើឲ្យក្រុមគ្រួសារខ្ញុំមានជីវភាពល្អប្រសើរ និងមានឪកាសប្រកបអាជីវកម្មនេះ » ។



**លោក ជា ឡាយ និង អ្នកស្រី សូ លាន**

លោក ជា ឡាយ មានអាយុ៥១ឆ្នាំ និងអ្នកស្រី សូ លាន អាយុ ៤៧ឆ្នាំ ពួកគេទាំងពីរជាប្តីប្រពន្ធនឹងគ្នាដែលមានទីលំនៅបច្ចុប្បន្ននៅភូមិពាមក្នុង ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ហើយមានកូនចំនួន២នាក់ គឺកូនស្រីទាំង២។ នៅឆ្នាំ២០០៧ លោក ជា ឡាយ និងអ្នកស្រី សូ លាន បានទិញដីកសិកម្មចំនួន២០ហិកតាទុកសម្រាប់ដាំស្វាយចន្ទី។ ពួកគេទាំងពីរបានតស៊ូព្យាយាមយ៉ាងស្វិតស្វាញក្នុងសកម្មភាពប្រចាំថ្ងៃ ដើម្បីដាំដំណាំស្វាយចន្ទី។

លោក ជា ឡាយ និងអ្នកស្រី សូ លាន បានចាប់ផ្ដើមប្រើប្រាស់កម្ចីវគ្គទី១ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ចំនួន២០១៨។ ក្នុងកម្ចីវគ្គទី១នេះ ពួកគេបានខ្ចីប្រាក់ ៥,០០០ដុល្លារអាមេរិក ដើម្បីភ្ជួររាស់ដី ទិញពូជដើមស្វាយចន្ទី និងទិញដីចំការ១០ហិកតាបន្ថែមទៀត។ ក្រោយមក ពួកគេបានខិតខំព្យាយាមក្នុងការកាប់គាស់រៀបចំដី និងដាំដំណាំស្វាយចន្ទី បន្ទាប់មកស្ថានភាពគ្រួសារ និងចំការរបស់ពួកគេបានរីកលូតលាស់ ហើយចំការពោរពេញទៅដោយដំណាំ។ ក្រោយមកទៀត ពួកគេបានសម្រេចខ្ចីប្រាក់វគ្គទី២ ពីគ្រឹះស្ថាន ទ្រព្យខ្ញុំ ចំនួន ១០,០០០ ដុល្លារអាមេរិក ដើម្បីកាប់គាស់លើដីចំការចំនួន១០ ហិកតាបន្ថែមទៀត ទិញដី និងដាំដំណាំស្វាយចន្ទីបន្ថែមផងដែរ។

បច្ចុប្បន្ននេះ លោក ជា ឡាយ និង អ្នកស្រី សូ លាន គឺជាអតិថិជនល្អម្នាក់ដែលអាចបង់សងបានទាន់ពេលវេលា ហើយពួកគេមានលទ្ធភាពខ្ពស់ និងមានស្ថេរភាពនៃប្រាក់ចំណូលពីដំណាំស្វាយចន្ទី។

លោក ជា ឡាយ និង លោកស្រី សូ លាន បានរៀបរាប់ថា « ខ្ញុំនឹងបន្តប្រើប្រាស់ប្រាក់កម្ចីពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ដោយសារតែសេវាកម្មរបស់គ្រឹះស្ថានមានលក្ខណៈរហ័សទាន់ចិត្ត និងលក្ខខណ្ឌងាយស្រួល ហើយបុគ្គលិកមានភាពរស់រាយរាក់ទាក់ផងដែរ។ កាលពីមុនមក ខ្ញុំមិនធ្លាប់ខ្ចីប្រាក់ពីធនាគារណាឡើង គឺធ្លាប់តែខ្ចីប្រាក់ពីអ្នកផ្ដល់កម្ចីឯកជន ហើយទទួលបានទំហំកម្ចីតិចតួចមិនគ្រប់តាមតម្រូវការរបស់ខ្ញុំឡើយ។ ប៉ុន្តែសព្វថ្ងៃនេះ អ្វីគ្រប់យ៉ាងមានភាពល្អប្រសើរឡើង ហើយខ្ញុំសូមអរគុណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ដែលត្រូវកម្ចីដល់គ្រួសាររបស់ខ្ញុំ ដោយសារតែកម្ចីនេះហើយ ទើបធ្វើឲ្យក្រុមគ្រួសាររបស់ខ្ញុំមានដីចំការច្រើនដូចសព្វថ្ងៃនេះ។

## ១៧. ផលិតផល និងសេវាកម្ម

### កម្ចីជាក្រុម

កម្ចីជាក្រុម គឺកម្ចីដែលត្រូវបានបង្កើតឡើងដើម្បីបំពេញនូវតម្រូវការរបស់អតិថិជន ដែលប្រកបអាជីវកម្មខ្នាតតូច និងប្រកបរបរកសិកម្មដូចជា ទិញដី និងដាំដំណាំផ្សេងៗ។ ផលិតផលនេះអាចឲ្យអតិថិជនទិញសម្ភារប្រើប្រាស់ ឬ ឧបករណ៍ចាំបាច់ផ្សេងៗទៀត ហើយគ្រឹះស្ថានមានទំហំកម្ចីកម្រិតអតិបរមាសម្រាប់កម្ចីជាក្រុម រហូតដល់ទឹកប្រាក់ចំនួន ៥០០ ដុល្លារអាមេរិក ឬ កម្ចីជាប្រាក់រៀលទទួលបានរហូតដល់ ២,០០០,០០០រៀល។

### កម្ចីកសិកម្ម

កម្ចីកសិកម្ម គឺត្រូវបានបង្កើតឡើង ដើម្បីបំពេញតម្រូវការអតិថិជន សម្រាប់ប្រកបការងារកសិ កម្មដូចជា៖ ទិញដី ទិញដីកសិកម្ម ដាំដំណាំ ភ្ជួររាស់ដី និងទិញបរិក្ខារកសិកម្មផ្សេងៗទៀត។ ផលិតផលកម្ចីកសិកម្ម មានគោលបំណងផ្ដល់ជូនអតិថិជនទាំងអស់នូវកម្ចីដែលមានលក្ខណៈលឿន រហ័សទាន់ចិត្ត និងលក្ខខណ្ឌងាយស្រួល ក្នុងការប្រកបសកម្មភាពការងារកសិកម្ម។ គ្រឹះស្ថានមានទំហំកម្ចីកម្រិតអតិបរមាសម្រាប់កម្ចីកសិកម្មពីទឹកប្រាក់ **២៥០$** រហូតដល់ **៣០,០០០$** ឬកម្ចីជាប្រាក់រៀលទឹកប្រាក់ចាប់ពី**១,០០០,០០០រៀល**ដល់**១២០,០០០,០០០រៀល**។

### កម្ចីសម្រាប់ជំនួញ

កម្ចីសម្រាប់ជំនួញ គឺត្រូវបានរៀបចំឡើងសម្រាប់បំពេញតម្រូវការឯកត្តបុគ្គល ឬសហគ្រិន និងក្រុមហ៊ុនអាជីវកម្មខ្នាតតូចឲ្យទទួលបានដើមទុន ឬមូលនិធិបន្ថែម សម្រាប់ពង្រីកប្រតិបត្តិការអាជីវកម្មរបស់ខ្លួនបន្ថែមទៀត។ គ្រឹះស្ថានមានទំហំកម្ចីកម្រិតអតិបរមា ចំពោះកម្ចីសម្រាប់ជំនួញនេះ ចាប់ពីទឹកប្រាក់**១,០០០$** ដល់**៣០,០០០$** ឬកម្ចីជាប្រាក់រៀលទឹកប្រាក់ ចាប់ពី**៤,០០០,០០០រៀល** រហូតដល់**១២០,០០០,០០០រៀល**។

### កម្ចីសម្រាប់ទិញម៉ូតូ

កម្ចីសម្រាប់ទិញម៉ូតូ គឺត្រូវបានបង្កើតឡើងសម្រាប់បំពេញតម្រូវការរបស់អតិថិជន ដែលមានបំណងចង់បានម៉ូតូ សម្រាប់ប្រើប្រាស់ធ្វើជាមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន ឬក្នុងគោលបំណងផ្សេងៗទៀត។ ផលិតផលមួយនេះបានជួយដល់ក្រុមគ្រួសារអតិថិជនជាច្រើនដែលកំពុងរស់នៅក្នុងតំបន់គោលដៅដែលគ្រឹះស្ថានកំពុងធ្វើប្រតិបត្តិការឲ្យមានម៉ូតូប្រើប្រាស់ជាលក្ខណៈកម្មសិទ្ធិផ្ទាល់ខ្លួនប្រកបដោយភាពងាយស្រួល ដោយគ្រាន់តែអតិថិជនមានទឹក

ប្រាក់សម្រាប់បង់មុនបន្តិចបន្តួចតែប៉ុណ្ណោះ។ គ្រឹះស្ថានមានទំហំកម្ចីកម្រិតអតិបរមា ចំពោះកម្ចីសម្រាប់ទិញម៉ូតូនេះ ពី**៥០០$** រហូតដល់**៤,៥០០$** ឬកម្ចីជាប្រាក់រៀលចាប់ពី**២,០០០,០០០រៀល** រហូតដល់**១៨,០០០,០០០រៀល**។

**កម្ចីសម្រាប់ទិញរថយន្ត**

កម្ចីសម្រាប់ទិញរថយន្ត គឺត្រូវបានបង្កើតឡើងដើម្បីបំពេញតម្រូវការរបស់អតិថិជន ដែលមានបំណងចង់បានរថយន្តសម្រាប់ប្រើប្រាស់ធ្វើជាមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន ឬក្នុងគោលបំណងផ្សេងៗទៀត។ ផលិតផលមួយនេះបានជួយដល់ក្រុមគ្រួសារអតិថិជនជាច្រើនដែលកំពុងរស់នៅក្នុងតំបន់ប្រតិបត្តិការឲ្យទទួលបានរថយន្តប្រើប្រាស់ជាលក្ខណៈកម្មសិទ្ធិផ្ទាល់ខ្លួនប្រកបដោយភាពងាយស្រួល ដោយគ្រាន់តែអតិថិជនមានសាច់ប្រាក់សម្រាប់បង់មុនបន្តិចបន្តួចតែប៉ុណ្ណោះ។ គ្រឹះស្ថានមានទំហំកម្ចីកម្រិតអតិបរមា ចំពោះកម្ចីសម្រាប់ទិញរថយន្តនេះ ចាប់ពី ១,០០០$រហូតដល់៣០,០០០$ ឬកម្ចីជាប្រាក់រៀលពី៤,០០០,០០០រៀល រហូតដល់១២០,០០០,០០០រៀល។

**កម្ចីសម្រាប់កែលំអរលំនៅដ្ឋាន**

កម្ចីសម្រាប់កែលំអរលំនៅដ្ឋាន គឺត្រូវបានរៀបចំឡើងសម្រាប់បំពេញតម្រូវការរបស់ក្រុមគ្រួសារអតិថិជនដែលមានបំណងចង់បានគេហដ្ឋានថ្មី ឬកែលំអរលំនៅដ្ឋានដែលមានស្រាប់របស់ខ្លួន។ គ្រឹះស្ថានមានទំហំកម្ចីកម្រិតអតិបរមាចំពោះកម្ចីសម្រាប់កែលំអរលំនៅដ្ឋាននេះ ចាប់ពីទឹកប្រាក់ចំនួន ១,០០០$ រហូតដល់៣០,០០០$ ឬកម្ចីជាប្រាក់រៀលទឹកប្រាក់ចាប់ពី**៤,០០០,០០០រៀល** ដល់**១២០,០០០,០០០រៀល**។





## ១៨. កិច្ចគាំពារអតិថិជន

ការយកចិត្តទុកដាក់ជាមួយអតិថិជន គឺជាយុទ្ធសាស្ត្រអាទិភាពមួយក្នុងចំណោមយុទ្ធសាស្ត្រអាទិភាពកំពូលៗរបស់គ្រឹះស្ថាន។ ទ្រព្យខ្ញុំ តែងតែស្តាប់នូវបញ្ហារបស់អតិថិជន និងព្យាយាមដោះស្រាយឲ្យអស់ពីលទ្ធភាព គ្រប់បញ្ហាទាំងអស់ដែលបានលើកឡើងដោយអតិថិជន។ ដើម្បីចូលរួមដោះស្រាយបញ្ហាឲ្យមានប្រសិទ្ធភាព ទ្រព្យខ្ញុំ បានបង្កើតនូវគោលនយោបាយដោះស្រាយបណ្តឹងអតិថិជន ដែលបានផ្តល់ជូនខិតបណ្ណ និងបង្ហាញនូវនីតិវិធីនានា ក្នុងការគ្រប់គ្រង និងដោះស្រាយបណ្តឹងអតិថិជន។ ដោយក្នុងនោះយើងបានកំណត់លេខទូរស័ព្ទសម្រាប់ករណីបន្ទាន់ (Hot Line) ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជន និងសាធារណជនទាំងអស់ អាចទាក់ទងមកកាន់អ្នកផ្តល់ព័ត៌មានបាន។ ក្នុងកិច្ចគាំពារអតិថិជន ព័ត៌មានដែលមានភាពច្បាស់លាស់ និងតម្លាភាពអំពីផលិតផល និងសេវាកម្មរបស់ ទ្រព្យខ្ញុំ ត្រូវបានដាក់តាំងបង្ហាញជាសាធារណៈ ដើម្បីផ្តល់ជូននូវផលប្រយោជន៍ទៅវិញទៅមក ហើយក្នុងការិយបរិច្ឆេទនៃរបាយការណ៍នេះ គ្រឹះស្ថានពុំទាន់មានពាក្យបណ្តឹងណាមួយពីអតិថិជននៅឡើយទេ។



## ១៩. ឥណទានរៀបចំឡើងវិញ

ក្នុងការផ្តល់ការអនុគ្រោះដល់អតិថិជនដែលជួបប្រទះការលំបាកក្នុងការបង់សងប្រាក់កម្ចី ដែលរងផលប៉ះពាល់ពីការឆ្លងរាលដាលនៃ ជំងឺកូវីដ-១៩ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាស ស្តីពីការអនុញ្ញាតឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ រៀបចំឥណទានឡើងវិញសម្រាប់អតិថិជន ដែលគ្មានលទ្ធភាពបង់សងប្រាក់កម្ចីបានទាន់ពេល ដោយសារការបាត់ បង់នូវប្រភពប្រាក់ចំណូល។ ដើម្បីអនុវត្តតាមបទប្បញ្ញត្តិដែលបានដាក់ចេញឲ្យអនុវត្តនេះ ទ្រព្យខ្ញុំ បានបង្កើតនូវគោលនយោបាយរៀបចំឥណទានឡើងវិញ ដើម្បីផ្តល់ការអនុគ្រោះដល់អតិថិជនដែលរងផលប៉ះពាល់ដោយសារការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ គោលនយោបាយនេះផ្តល់លក្ខខណ្ឌដល់អតិថិជនឲ្យទទួលបាន ការបន្តរយៈពេលសងកាន់តែវែងជាងមុន និងកែប្រែរបៀបសងប្រាក់ថ្មី ដោយសងតែការប្រាក់ ហើយប្រាក់ដើមត្រូវសងនៅរយៈពេលកំណត់ជាក់លាក់ណាមួយ។យន្តការនេះបានផ្តល់លក្ខខណ្ឌងាយ ស្រួលដល់អតិថិជនជាច្រើនដែលបានដាក់ពាក្យស្នើសុំរៀបចំឥណទានឡើងវិញរបស់ពួកគេ។ ក្នុងការផ្តល់លក្ខខណ្ឌអនុគ្រោះនេះដែរ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បានរៀបចំឥណទានឡើងវិញរហូតដល់ ១៦៨ គណនីអតិថិជន ដែលមានឥណទានសរុបរហូតដល់ ៥៩២,៥៥៤ ដុល្លារអាមេរិក ដែលមានតម្លៃស្មើទៅនឹង ២,៣៩៧ លានរៀល។

## ២០. ការចូលរួមបរិច្ចាគថវិកាជួយសង្គម

នៅក្នុងឆ្នាំ២០២០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក បានចូលរួមបរិច្ចាកនូវស្បៀងសម្រាប់សង្គ្រោះបន្ទាន់ដល់រដ្ឋបាលខេត្តបន្ទាយមានជ័យផងដែរ ដោយក្នុងនោះស្បៀងសម្រាប់សង្គ្រោះបន្ទាន់រួមមានៈ អាហារ និងទឹកពិសារផងដែរ ដើម្បីចែកជូនទៅជនរងគ្រោះដោយសារគ្រោះទឹកជំនន់ ដែលបណ្តាលមកពីជំនន់ទឹកភ្លៀងធ្ងន់ធ្ងរនៅក្នុងអំឡុងខែតុលា ឆ្នាំ២០២០។ នៅក្នុងអំឡុងពេលនោះដែរ យើងបានឧបត្ថម្ភជំនួយសង្គ្រោះបន្ទាន់បីប្រភេទដូចជាៈ អង្ករ មីកញ្ចប់ និងទឹកសម្រាប់ពិសារផងដែរ។ សម្រាប់ជំនួយមនុស្សធម៌ទាំងនេះ គឺអាចជួយកាត់បន្ថយទុក្ខលំបាក និងកង្វះខាតស្បៀងអាហាររយៈពេលខ្លី សម្រាប់ជនរងគ្រោះដោយសារទឹកជំនន់នេះផងដែរ។ ការបរិច្ចាកស្បៀងសង្គ្រោះបន្ទាន់ គឺជាផ្នែកមួយនៃការចូលរួមចំណែកជួយសង្គមដែល ទ្រព្យខ្ញុំ បានធ្វើឡើង ដើម្បីជួយកាត់បន្ថយទុក្ខលំបាករបស់ប្រជាជនដែលរងគ្រោះរបស់ពួកយើង។



## ២១. ការគ្រប់ដណ្តប់ប្រតិបត្តិការ

សម្រាប់ឆ្នាំ២០២០ គឺជាឆ្នាំដែលមានបញ្ហាប្រឈមខ្លាំងដោយសារតែការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាសកលត្រូវបានផ្ទុះឡើង ហើយនៅក្នុងនោះប្រទេសកម្ពុជាក៏ជាប្រទេសមួយ ក្នុងចំណោមប្រទេសជាច្រើនលើសកលលោក ដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ ពីជំងឺរាតត្បាតដ៏កាចសាហាវនេះផងដែរ សម្រាប់ប្រទេសកម្ពុជាយើង ជំងឺកូវីដ-១៩ ចាប់ផ្តើមឆ្លងរីករាលដាលនៅដើមឆ្នាំ២០២០ ហើយបញ្ហានេះបានផ្តល់ផលប៉ះពាល់ធ្ងន់ធ្ងរដល់សកម្មភាពក្នុងការគ្របដណ្តប់ប្រតិបត្តិការរបស់ពួកយើងផងដែរ។ ដើម្បីទប់ទល់នឹងស្ថានភាពនេះ **ទ្រព្យខ្ញុំ** បានសម្រេចរក្សាប្រតិបត្តិការអាជីកម្មក្នុងតំបន់ដែលគ្រឹះស្ថានកំពុងធ្វើសកម្មភាពប្រតិបត្តិការ ដូចនឹងឆ្នាំ២០១៩ផងដែរ។ ក្នុងការិយបរិច្ឆេទនៃរបាយការណ៍នេះ **ទ្រព្យខ្ញុំ** ពុំបានពង្រីកប្រតិបត្តិការបន្ថែមទៀតនោះឡើយទាំងការិយាល័យសាខា និងតំបន់ប្រតិបត្តិការ ដោយយើងបានព្យាយាមអស់ពីលទ្ធភាព នៅក្នុងការរក្សាប្រតិបត្តិការដែលមានស្រាប់របស់យើងពេញមួយឆ្នាំ។

នៅក្នុងការិយបរិច្ឆេទនៃរបាយការណ៍នេះ **ទ្រព្យខ្ញុំ** បានបន្តធ្វើសកម្មភាពប្រតិបត្តិការរបស់ខ្លួន ជាមួយនឹងការិយាល័យសាខាទាំង៥សាខា ហើយការិយាល័យសាខាទាំងអស់នោះស្ថិតនៅខេត្តភាគពាយព្យនៃប្រទេសកម្ពុជារួមមានៈខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តឧត្តរមានជ័យ។ ការិយាល័យសាខានីមួយៗមានបុគ្គលិកដែលមានគុណវុឌ្ឍិគ្រប់គ្រាន់បំពេញការងារ និងបំពាក់ទៅដោយបរិក្ខាចាំបាច់ៗ ដើម្បីជម្រុញឲ្យប្រតិបត្តិការមានដំណើរការល្អ។

នៅចុងឆ្នាំ២០២០ **ទ្រព្យខ្ញុំ** បានគ្របដណ្តប់តំបន់ប្រតិបត្តិការរហូតដល់ **២៨ ស្រុក ១៥៧ឃុំ** និង**៨១០ភូមិ** ដែលស្ថិតក្នុងខេត្តបន្ទាយាមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង។ **ទ្រព្យខ្ញុំ** មានធនធានមនុស្សខ្លាំងក្លា ដែលអាចនាំយកផលិតផល ឬសេវាកម្មទៅកាន់ភូមិដាច់ស្រយាល និងឃុំជាច្រើនក្នុងខេត្តទាំងបីនេះ បើទោះបីជា **ទ្រព្យខ្ញុំ** មានចំនួនធនធានមនុស្សតិចនៅឡើយក៏ដោយ។ កត្តាទាំងនេះអាចសរបញ្ជាក់បានថា ធនធានមនុស្សរបស់យើងមានការតាំងចិត្ត និងពុះពារខ្ពស់ ក្នុងការបង្កើនសកម្មភាពគ្របដណ្តប់តំបន់ប្រតិបត្តិការបានជំទូលំទូលាយ។

តាមរយៈកិច្ចខិតខំប្រឹងប្រែងចំពោះប្រតិបត្តិការ **ទ្រព្យខ្ញុំ** ទទួលបានអតិថិជនចំនួន **៣,៧៩៨ គណនី** រួមជាមួយនឹងផលបត្រកម្ចីសរុបរហូតដល់ **៦,១២៨,៧៨១ ដុល្លារអាមេរិក (៣៩.១% គឺជាស្ត្រី)** ចំពោះលទ្ធផលនេះ បានបង្ហាញអំពីការថយចុះនៃចំនួនអតិថិជន និងផលបត្រកម្ចី ដោយសារតែការផ្អាកបញ្ចេញកម្ចីអស់រយៈពេលជាច្រើនខែ នៅក្នុងឆ្នាំ២០២០។



## ២២. លទ្ធផលប្រតិបត្តិការឥណទាន

សម្រាប់ឆ្នាំ២០២០ **ទ្រព្យខ្ញុំ** បាននាំយកផលិតផលសំខាន់ៗចំនួន០៨ប្រភេទចូលទៅកាន់ទីផ្សារ ដើម្បីបំពេញនូវតម្រូវការអតិថិជនដែលស្ថិតក្នុងតំបន់ដែលគ្រឹះស្ថានកំពុងតែធ្វើប្រតិបត្តិការ។ **ទ្រព្យខ្ញុំ** ផ្តល់ជូនអតិថិជនទាំងអស់នូវផលិតផលដែលមានលក្ខណៈសំបូរបែបដែលផលិតផលទាំងនោះត្រូវបានរៀបចំឡើង ដើម្បីទាក់ទាញតម្រូវការទីផ្សារ ដោយក្នុងនោះរួមមានៈ កម្ចីកសិកម្ម កម្ចីសម្រាប់ជំនួញ កម្ចីសម្រាប់កែលំអរលំនៅដ្ឋាន កម្ចីសម្រាប់ទិញម៉ូតូ និងកម្ចីសម្រាប់ទិញរថយន្ត និងកម្ចីជាក្រុម។ ផលិតផលកម្ចីទាំងអស់ត្រូវបានលក់និងផ្សព្វផ្សាយព័ត៌មានដល់ អតិថិជនក្នុងតំបន់គោលដៅផងដែរ។ គិតត្រឹមខែធ្នូ ឆ្នាំ២០២០ នៅក្នុងតារាងលទ្ធផលប្រតិបត្តិការខាងក្រោម បានបង្ហាញឲ្យឃើញថា កម្ចីសម្រាប់ទិញម៉ូតូមានចំនួនច្រើនជាងគេបង្អស់ ហើយបន្ទាប់មកគឺកម្ចីកសិកម្ម។ ដូច្នេះ ផែនការបន្ទាប់របស់គ្រឹះស្ថាន យើងនឹងផ្តោត ហើយចាត់ជាអាទិភាពចំពោះកម្ចីសម្រាប់ទិញម៉ូតូ និងកម្ចីកសិកម្ម។ ព័ត៌មានលំអិតអំពីផលិតផល ចំនួនគណនីអតិថិជន និងផលបត្រកម្ចីមានបង្ហាញដូចខាងក្រោមៈ

| ផលិតផលឥណទាន | ឥណទានទោល | | |
|---|---|---|---|
| | ចំនួនគណនី | ដុល្លារអាមេរិក | លានរៀល |
| ម៉ូតូ | 2,103 | 1,723,877 | 6,973 |
| ត្រាក់ទ័រ | 25 | 200,071 | 809 |
| គោយន្ត | 13 | 18,819 | 76 |
| រថយន្តដឹកទំនិញ | 12 | 95,837 | 388 |
| រថយន្តតូច និងគ្រឿងចក្រ | 241 | 945,520 | 3,825 |
| កម្ចីផ្ទាល់ខ្លួន | 257 | 710,758 | 2,875 |
| កម្ចីកសិកម្ម | 883 | 1,736,197 | 7,023 |
| កម្ចីកែលំអរលំនៅដ្ឋាន | 264 | 697,702 | 2,822 |
| សរុប | 3798 | 6,128,781 | 24,791 |



## ២៣. បណ្តាញសាខា

នៅចុងឆ្នាំ២០២០**ទ្រព្យខ្ញុំ** បានធ្វើប្រតិបត្តិការរបស់ខ្លួនដោយមានការិយាល័យសាខាចំនួន០៥សាខា ដែលការិយា ល័យទាំងនោះស្ថិតនៅខេត្តចំនួន០៣ផ្សេងៗគ្នា (ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង) គ្រឹះស្ថានមានការិយាល័យកណ្តាលស្ថិតក្នុងអាគារតែមួយ ជាមួយនឹងសាខាខេត្តបន្ទាយមានជ័យ។ ចំពោះការិយាល័យទាំង០៥សាខា របស់គ្រឹះស្ថាន មានការិយាល័យសាខាស្រុកចំនួន០២ គឺ ស្រុកថ្មពួក និងស្រុកអន្លង់វែង តាមរយៈការធ្វើសកម្មភាពការងារ ជាមួយបណ្តាញប្រតិបត្តិការនេះ **ទ្រព្យខ្ញុំ** អាចដំណើរការផលិតផល និងសេវាកម្មបានតាមរយៈមន្រ្តីឥណទាន និងបុគ្គលិកសំខាន់ៗមួយចំនួន ដើម្បីគ្របដណ្តប់ប្រតិបត្តិការទូទាំងឃុំ និងស្រុកនៅក្នុងខេត្តនីមួយៗ។



## ២៤. បណ្តាញសាខា និងតំបន់ប្រតិបត្តិការ

| | 2020 | 2019 | 2018 | 2017 |
|---|---|---|---|---|
| ចំនួនសាខា | 5 | 4 | 4 | 1 |
| ខេត្ត | 3 | 3 | 3 | 1 |
| ស្រុក | 28 | 28 | 24 | 9 |
| ឃុំ | 157 | 157 | 142 | 60 |
| ភូមិ | 810 | 810 | 744 | 286 |
| ចំនួនអ្នកខ្ចី | 3,798 | 5,014 | 5,101 | 4,252 |

## ២៥. ធនធានមនុស្ស

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ទ្រព្យខ្ញុំ បានធ្វើសកម្មភាពប្រតិបត្តិការរបស់ខ្លួន ដោយមានបុគ្គលិកសរុបចំនួន **៩៣នាក់** (បុគ្គលិក **៣៨.៧%** ជាស្ត្រី) ហើយពួកគេទាំងអស់ត្រូវបានបម្រើការងារក្នុងចំណោមសាខាទាំង០៥ ដោយនៅក្នុងនោះរួមមាន: ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តឧត្តរមានជ័យ។ យើងបានសង្កេតឃើញថា ចំនួនបុគ្គលិកមានកំណើនចំនួន**២.១៩%** បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩។ ពីមួយឆ្នាំទៅមួយឆ្នាំ **ទ្រព្យខ្ញុំ** មានកំណើនគួរកត់សម្គាល់ចំពោះកំណើនបុគ្គលិក ហើយបុគ្គលិកទាំងអស់ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ផ្នែកធនធានមនុស្ស ដែលជាអ្នកទទួលបន្ទុកក្នុងការជួល បណ្តុះបណ្តាល បង្វឹក និងវាយតម្លៃលទ្ធផលការងារ ដោយអនុលោមទៅតាមគោលនយោបាយធនធានមនុស្សរបស់គ្រឹះស្ថាន។ ក្រោយពី គ្រឹះស្ថានបានជ្រើសរើសបុគ្គលិករួចគ្រប់បុគ្គលិកទាំងអស់បានទទួលនូវការ បណ្តុះបណ្តាលស្តីពីការងារ ការបង្វឹក និងការតម្រង់ទិសដៅការងារទៅតាមមុខងាររៀងៗខ្លួន។ លើសពីនេះ អភិបាលកិច្ច និងតម្លាភាពនៅកន្លែងការងារត្រូវបានធ្វើឡើង ដើម្បីធានាឲ្យមានបរិយាកាសការងារល្អ និងសុខុមាលភាពបុគ្គលិកផងដែរ។

ផ្អែកលើរបាយការណ៍ចលនាបុគ្គលិក បានបង្ហាញឲ្យឃើញថា ក្នុងឆ្នាំ២០២០មានអត្រាបុគ្គលិកលាឈប់ពីការងារចំនួន៥.៣៧% ខណៈពេលដែលអត្រាបុគ្គលិកចូលបម្រើការងារថ្មី មានអត្រាកើនឡើងរហូតដល់៨.៦០%។ ចំពោះអត្រានេះ គឺមានកម្រិតទាប បើធៀបទៅនឹងឆ្នាំ២០១៩។ អត្រាបុគ្គលិកលាឈប់ពីការងារក្នុងឆ្នាំ២០២០ បានបង្ហាញឲ្យឃើញថាមានអត្រាអាចទទួលយកបានក្នុងកម្រិត៥.៣៧%ដែលជាទូទៅយើងសង្កេតឃើញថា លក្ខខណ្ឌធនធានមនុស្សរបស់យើង គឺមានស្ថេរភាព។ ចំពោះអត្រានេះអាចបង្ហាញថា គុណភាពនៃការគ្រប់គ្រងធនធានមនុស្សមានបរិយាកាសល្អនៅកន្លែងការងារផងដែរ។ សម្រាប់គោលនយោបាយធនធានមនុស្សរបស់ គ្រឹះស្ថានបានផ្តល់តម្លៃដល់បុគ្គលិក ប្រកបដោយស្មើភាពគ្នាក្នុងការតំឡើងឋានៈ គឺធ្វើឡើងដោយផ្អែកទៅលើស្មារតីអនុវត្តការងារ និងគុណវុឌ្ឍរបស់បុគ្គលិក។ លើសពីនេះ **ទ្រព្យខ្ញុំ** បានបង្កើតការជម្រុញលើកទឹកចិត្តបុគ្គលិក ដោយផ្អែកលើលទ្ធផលការងារ ដើម្បីបង្កើនផលិតភាពការងារ ក៏ដូចជាលើកទឹកចិត្តដល់អ្នកដែលមានស្នាដៃល្អនៅក្នុងការងារផងដែរ។


"If today were the last day of my life
Would I want to do what I'm about to do today?"
Steve Jobs

## បុគ្គលិកដែលជ្រើសរើសថ្មីក្នុងឆ្នាំ២០២០




## អត្រាបុគ្គលិកលាឈប់ពីការងារឆ្នាំ២០២០



## ២៦. ការអភិវឌ្ឍន៍ និងកសាងសមត្ថភាពបុគ្គលិក

ការអភិវឌ្ឍន៍សមត្ថភាពរបស់បុគ្គលិក ត្រូវបានចាត់ទុកថាជាឆ្អឹងខ្នងនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ហើយក្នុងឆ្នាំ២០២០ គ្រឹះស្ថានបានប្រើប្រាស់ថវិកាមួយចំនួនសម្រាប់ធ្វើការអភិវឌ្ឍន៍ និងកសាងសមត្ថភាពបុគ្គលិករបស់គ្រឹះស្ថាន។ ពីមួយឆ្នាំទៅមួយឆ្នាំ បុគ្គលិកទាំងអស់ត្រូវបានផ្តល់វគ្គបណ្តុះបណ្តាលបំពាក់បំប៉នបន្ថែមពាក់ព័ន្ធទៅនឹងមុខងាររៀងៗខ្លួន និងការតម្រង់ទិសដៅការងារ ព្រមទាំងការបង្វឹកបន្ថែមពីជំនាញដែលចាំបាច់នានាផ្អែកលើលទ្ធផលនៃការប៉ាន់ប្រមាណអំពីតម្រូវការបណ្តុះបណ្តាលរួចមក។

គ្រឹះស្ថាន **ទ្រព្យខ្ញុំ** បានបង្កើតវិធីសាស្ត្រពីរបែបក្នុងការបណ្តុះបណ្តាលបុគ្គលិក (១) បញ្ជូនបុគ្គលិកទៅចូលរួមវគ្គបណ្តុះបណ្តាលតាមស្ថាប័ន បណ្តុះបណ្តាលដែលមានវិជ្ជាជីវៈខ្ពស់ និង (២) បើកវគ្គបណ្តុះបណ្តាលក្នុងគ្រឹះស្ថាន តាមរយៈការបន្តផ្តល់វគ្គតម្រង់ទិសដៅការងារ ការបង្វឹក ប្រជុំពិភាក្សា ការបណ្តុះបណ្តាល និងសិក្ខាសាលាផ្លាស់ប្តូរនូវបទពិសោធន៍ការងារ។ ក្នុងការិយបរិច្ឆេទនៃរបាយការណ៍នេះ គ្រឹះស្ថានបានបញ្ជូនបុគ្គលិកសរុបចំនួន **២១រូប** ទៅចូលរួមវគ្គបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅរាជធានីភ្នំពេញ។ វគ្គបណ្តុះបណ្តាលទាំងអស់នេះ បានចូលរួមចំណែកក្នុងការបង្កើនចំណេះដឹង និងជំនាញរបស់បុគ្គលិកចំនួន២១រូប ឲ្យមានភាពល្អប្រសើរជាងមុនផងដែរ។ ក្រៅពីវគ្គបណ្តុះបណ្តាលខាងក្រៅទាំងនោះ ទ្រព្យខ្ញុំតែងតែបង្កើតកម្មវិធីតម្រង់ទិសដៅផ្ទៃក្នុងដល់បុគ្គលិកទាំងអស់ ក្នុងគោលបំណងជម្រុញឲ្យពួកគេកាន់តែយល់ដឹងច្បាស់លាស់ស្តីអំពីការងារ។ ចំពោះព័ត៌មានលំអិតស្តីអំពីវគ្គបណ្តុះបណ្តាលទាំងអស់មានបង្ហាញដូចខាងក្រោម៖

| ល.រ | ប្រធានបទ | ចំនួនអ្នកចូលរួម | ស្ថាប័ន |
|---|---|---|---|
| 1 | ជំនាញសវនកម្មផ្ទៃក្នុង | 1 | ប៊ែមប៊ូ ហ្វាយនែន ភីអិលស៊ី |
| 2 | ការប្រកាសពន្ធអាជីវកម្មតាមអនឡាញ | 1 | សាលាជាតិពន្ធដារ |
| 3 | គន្លឹះជោគជ័យក្នុងការបញ្ចេញឥណទានធ្វើឲ្យ PAR ស្មើសូន្យ | 9 | វិទ្យាស្ថានពាណិជ្ជសាស្រ្ត អេស៊ីលីដា |
| 4 | ការវាយតម្លៃអចលនទ្រព្យសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | 4 | វិទ្យាស្ថានពាណិជ្ជសាស្រ្ត អេស៊ីលីដា |
| 5 | ការគ្រប់គ្រងកម្ចីយឺតយ៉ាវ | 4 | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា |
| 6 | ការប្រឆាំងបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | 1 | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា |
| 7 | ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | 1 | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |



## ២៧. របាយការណ៍ហិរញ្ញវត្ថុ

### ២៧ .១ របាយការណ៍ក្រុមប្រឹក្សាភិបាល

### របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមធ្វើការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនដោយភ្ជាប់ជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020។

**សកម្មភាពចម្បង**

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺធ្វើប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ។ ពុំមានការប្រែប្រួលជាសារវន្តទៅលើសកម្មភាពចម្បងនៅក្នុងការិយបរិច្ឆេទនេះទេ។

**លទ្ធផលនៃហិរញ្ញវត្ថុ**

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

| | 2020 | | 2019 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) |
| ប្រាក់(ខាត)/ចំណេញមុនដកពន្ធ | (204,540) | (833,910) | 256,870 | 1,040,837 |
| ពន្ធលើប្រាក់ចំណេញ | (3,928) | (16,014) | (53,216) | (215,631) |
| ប្រាក់(ខាត)/ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | (208,468) | (849,924) | 203,654 | 825,206 |

**ភាគលាភ**

ពុំមានភាគលាភណាត្រូវបានប្រកាស ឬត្រូវបានបង់ ហើយក្រុមប្រឹក្សាភិបាលក៏ពុំបានផ្តល់ជាអនុសាសន៍ឲ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនោះទេ។

**ដើមទុន**

ដើមទុនដែលបានបង់របស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 មានចំនួន 1,500,000 ដុល្លារអាមេរិក (2019: 1,500,000 ដុល្លារអាមេរិក) ដែលក្នុងមួយភាគហ៊ុនស្មើនឹង 1 ដុល្លារអាមេរិក។ ភាគហ៊ុន និងរចនាសម្ព័ន្ធភាគហ៊ុនត្រូវបានលាតត្រដាងនៅកំណត់សម្គាល់ទី 14។

**ទុនបម្រុង និងសំវិធានធន**
ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

**ឥណទានអាក្រក់ និងឥណទានជាប់សង្ស័យ**
នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា វិធានការទាក់ទងនឹងការលុបចោលនូវឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាមិនមានឥណទានអាក្រក់ និងសំវិធានធនត្រូវបានធ្វើឡើងសម្រាប់ឥណទានជាប់សង្ស័យ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយដែលអាចនឹងបណ្តាលឲ្យចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានចំនួនខ្វះខាតជាសារវន្តនោះឡើយ។

**ទ្រព្យសកម្មចរន្ត**
នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលរំពឹងទុកថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

**វិធីសាស្ត្រកំណត់តម្លៃ**
នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលនឹងធ្វើឲ្យប៉ះពាល់ដល់វិធីសាស្ត្រកំណត់តម្លៃដែលបានអនុវត្តកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ ។

**បំណុលយថាភាព**
នាថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖
(ក) ការប្រែប្រួលទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាមួយចាប់តាំងពីដំណាច់ឆ្នាំឡើយ ឬ
(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញនៅក្នុង រយៈពេល 12 ខែ បន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលមិនបានរែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាល ក៏មានមតិផងដែរថានៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឲ្យប៉ះពាល់ដល់ លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សារវន្តកើតឡើងក្រោយកាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឲ្យមានការលាតត្រដាង ឬនិយ័តភាពក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយ នៅក្នុងកំណត់សម្គាល់ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបម្រើការនៅក្នុងការិយបរិច្ឆេទនិងនាថ្ងៃចេញរបាយការណ៍នេះមានរាយនាមដូចខាងក្រោម៖

| | | |
|---|---|---|
| លោក **ឡែម ចាន់សំរេច** | ប្រធានក្រុមប្រឹក្សាភិបាល | (តែងតាំងនាថ្ងៃទី 13 ខែមករា ឆ្នាំ 2021) |
| លោក **លឹម សុជាតិ** | អភិបាល | (តែងតាំងនាថ្ងៃទី 13 ខែមករា ឆ្នាំ 2021) |
| លោក **ណា សុធី** | អភិបាលឯករាជ្យ | (តែងតាំងនាថ្ងៃទី 13 ខែមករា ឆ្នាំ 2021) |
| លោក **លឹម សុជាតិ** | ប្រធានក្រុមប្រឹក្សាភិបាល | (លាលែងនាថ្ងៃទី 13 ខែមករា ឆ្នាំ 2021) |
| លោក **សួរ អ៊ីយ៉ុង** | អភិបាល | (លាលែងនាថ្ងៃទី 13 ខែមករា ឆ្នាំ 2021) |
| លោកស្រី **ឈិន ផល្លា** | អភិបាល | (លាលែងនាថ្ងៃទី 13 ខែមករា ឆ្នាំ 2021) |

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

មិនមានសមាជិកក្រុមប្រឹក្សាភិបាល កាន់កាប់ភាគហ៊ុនដោយផ្ទាល់ ឬ ដោយប្រយោល នៅក្នុងការិយបរិច្ឆេទនេះឡើយ ។

**អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល**

មិនថានៅចុងការិយបរិច្ឆេទ ឬនៅក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬសាជីវកម្មដទៃ ឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃឆ្នាំកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរាប់បញ្ចូលក្នុងចំនួនសរុបនៃឯកត្តជនដែលបានទទួល ឬកំណត់ និងអាចទទួលបានដោយក្រុមប្រឹក្សាភិបាល) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុនជាមួយក្រុមប្រឹក្សាភិបាល ឬដោយក្រុមហ៊ុនផ្សេងដែលមានក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនផ្សេងដែលមានក្រុមប្រឹក្សាភិបាលជាសមាជិកនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ច្រើនជាងអ្វីត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

**ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ**

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (“CIFRS for SMEs”)។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។

(ខ) អនុលោមទៅតាម CIFRS for SMEs ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះដើម្បីបង្ហាញពីភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ និងពន្យល់ឲ្យបានច្បាស់លាស់ និងកំណត់ចំនួននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងការរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនចំពោះការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និង ប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃស្តង់ដារគណនេយ្យ លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់ជម្រះបញ្ជីក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចសំខាន់ៗទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលជានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការដូចដែលបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយដូចបានបង្ហាញនៅទំព័រទី 10 ដល់ 48 ថាបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម។

*ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល*

លោក **ខ្សែម ចាន់សំរេច**
*ប្រធានក្រុមប្រឹក្សាភិបាល*

បន្ទាយមានជ័យ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី20 ខែមេសា ឆ្នាំ 2021

## ២៧.២ របាយការណ៍របស់សវនករឯករាជ្យ
## ជូនចំពោះភាគទុនិក
## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក

### មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀត ដែលបានបង្ហាញនៅទំព័រទី 10 ដល់ 48។
ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញនូវភាពត្រឹមត្រូវ ក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ ក្រុមហ៊ុននាថ្ងៃទី31 ខែ ធ្នូ ឆ្នាំ 2020 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។

### មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំឯករាជ្យភាពពី ក្រុមហ៊ុនតាមតម្រូវការក្រមសីលធម៌ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញតាមក្របខណ្ឌទំនួលខុសត្រូវក្រមសីលធម៌ផ្សេងៗ ស្របតាមតម្រូវការទាំងនោះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

### បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀត ដែលបានបញ្ចេញមតិសវនកម្មនៅថ្ងៃទី 26 ខែ មិថុនា ឆ្នាំ 2020 ថារបាយការណ៍នោះមានភាពត្រឹមត្រូវ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រងមានការទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ មានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលនៅទំព័រ 1 ដល់ទី 5 ចំណែកឯរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនរំពឹងថានឹងផ្តល់ឲ្យយើងខ្ញុំក្រោយកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។

មតិរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុមិនបានគ្របដណ្តប់ព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំក៏មិនផ្តល់នូវអំណះអំណាងណាមួយលើព័ត៌មានផ្សេងៗទាំងនេះឡើយ។
ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុងឆ្គងជាសារវន្តឬទេ។ ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះអាចឲ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យលើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។
អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ
គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផលគឺជាអំណះអំណាងមានកម្រិតខ្ពស់មួយប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្តនៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នាមានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមន្ទិលជាតុនិយមក្នុងអំឡុងពេលសវនកម្ម។

យើងខ្ញុំក៏បាន៖

- ធ្វើការកំណត់ និង វាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ
- មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិត គ្នា ការលួចបន្លំ ការលុបចោលដោយចេតនាការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
- ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថា តើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិ ការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំគឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបាន ត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់នូវនិរន្តរភាពនៃអាជីវកម្ម។
- វាយតម្លៃលើការបង្ហាញរចនាសម្ព័ន្ធ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាននិងវាយតម្លៃថា តើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំបានផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច   ចំពោះកត្តាពាក់ព័ន្ធនឹងសវនកម្មរួមមានជាអាទិ៍ វិសាលភាព  និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម  និងការរកឃើញបញ្ហាសវនកម្មជាសារវន្ត រួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **អេហ្វអាយអាយ&អឹសូស៊ីអេត**

**ហេខ សិតា**

*នាយកគ្រប់គ្រង*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី20 ខែមេសា  ឆ្នាំ 2021

## ២៧.៣ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

*អនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*

| | 2020 | | 2019 | | 2018 | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | | |
| សាច់ប្រាក់ក្នុងដៃ | 13,854 | 56,039 | 29,803 | 121,447 | 287,799 | 1,156,376 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ | 76,070 | 307,703 | 75,877 | 309,199 | 75,425 | 303,058 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ | 2,445,407 | 9,891,671 | 404,775 | 1,649,458 | 72,919 | 292,989 |
| ឥណទានផ្តល់ដល់អតិថិជន | 5,969,280 | 24,145,738 | 8,279,721 | 33,739,863 | 8,067,551 | 32,415,420 |
| ទ្រព្យសកម្មផ្សេងៗ | 49,440 | 199,985 | 23,626 | 96,276 | 99,521 | 399,875 |
| ទ្រព្យ និងបរិក្ខារ | 19,724 | 79,784 | 22,429 | 91,398 | 18,033 | 72,457 |
| ទ្រព្យសកម្មអរូបី | 11,341 | 45,874 | 13,437 | 54,756 | 15,533 | 62,412 |
| ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ | 32,013 | 129,493 | 35,941 | 146,460 | 36,547 | 146,846 |
| **ទ្រព្យសកម្មសរុប** | **8,617,129** | **34,856,287** | **8,885,609** | **36,208,857** | **8,673,328** | **34,849,433** |
| **បំណុល និងមូលធន** | | | | | | |
| **បំណុល** | | | | | | |
| បំណុលផ្សេងៗ | 52,341 | 211,719 | 82,422 | 335,870 | 64,160 | 257,795 |
| បំណុលពន្ធអប្បរមា/ពន្ធលើប្រាក់ចំណេ | 3,960 | 16,018 | 33,891 | 138,106 | 32,276 | 129,685 |
| ប្រាក់កម្ចី | 6,862,500 | 27,758,813 | 6,862,500 | 27,964,688 | 6,873,750 | 27,618,728 |
| **បំណុលសរុប** | **6,918,801** | **27,986,550** | **6,978,813** | **28,438,664** | **6,970,186** | **28,006,208** |
| **មូលធន** | | | | | | |
| ដើមទុន | 1,500,000 | 6,000,000 | 1,500,000 | 6,000,000 | 1,500,000 | 6,000,000 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 84,881 | 343,344 | 115,623 | 468,504 | 88,727 | 358,901 |
| ប្រាក់ចំណេញរក្សាទុក | 113,447 | 453,823 | 291,173 | 1,178,412 | 114,415 | 462,809 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 72,570 | - | 123,277 | - | 21,515 |
| **មូលធនសរុប** | **1,698,328** | **6,869,737** | **1,906,796** | **7,770,193** | **1,703,142** | **6,843,225** |
| **បំណុល និងមូលធនសរុប** | **8,617,129** | **34,856,287** | **8,885,609** | **36,208,857** | **8,673,328** | **34,849,433** |

## ២៧.៤ របាយការណ៍លទ្ធផលពេញលេញ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

*អនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*

| | 2020 | | 2019 | | 2018 | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលពីការប្រាក់ | 1,702,647 | 6,941,692 | 1,984,518 | 8,041,267 | 1,953,646 | 7,902,498 |
| ចំណាយលើការប្រាក់ | (675,000) | (2,751,975) | (675,000) | (2,735,100) | (826,489) | (3,343,148) |
| **ចំណូលពីការប្រាក់សុទ្ធ** | **1,027,647** | **4,189,717** | **1,309,518** | **5,306,167** | **1,127,157** | **4,559,350** |
| ចំណូលប្រតិបត្តិការផ្សេងៗ | 79,676 | 324,839 | 58,166 | 235,689 | 56,268 | 227,604 |
| **ចំណូលប្រតិបត្តិការសរុប** | **1,107,323** | **4,514,556** | **1,367,684** | **5,541,856** | **1,183,425** | **4,786,954** |
| ចំណាយលើបុគ្គលិក | (751,658) | (3,064,510) | (740,627) | (3,001,021) | (626,138) | (2,532,728) |
| រំលស់លើទ្រព្យ និងបរិក្ខារ | (6,320) | (25,767) | (6,116) | (24,782) | (4,126) | (16,690) |
| រំលស់លើទ្រព្យសកម្មអរូបី | (2,096) | (8,545) | (2,096) | (8,493) | (2,096) | (8,478) |
| (ការខាតបង់) / តំហយលើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ | (69,516) | (283,417) | 17,310 | 70,140 | (29,485) | (119,267) |
| ចំណាយទូទៅ និងរដ្ឋបាល | (464,450) | (1,893,563) | (379,285) | (1,536,863) | (290,583) | (1,175,408) |
| ចំណាយពន្ធអប្បបរមា | (17,823) | (72,664) | | | | |
| **ប្រាក់ (ខាត)/ ចំណេញមុនដកពន្ធ** | **(204,540)** | **(833,910)** | **256,870** | **1,040,837** | **230,997** | **934,383** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (3,928) | (16,014) | 53,216 | 215,631 | 10,433 | 42,201 |
| **ប្រាក់ (ខាត)/ ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | **(208,468)** | **(849,924)** | **203,654** | **825,206** | **220,564** | **892,182** |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (50,532) | - | 101,762 | - | (34,123) |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | **(208,468)** | **(900,456)** | **203,654** | **926,968** | **220,564** | **858,059** |

## ២៧.៥ របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | 2020 | | 2019 | | 2018 | |
|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល* | *'ល្លារអាមេរិក* | *ពាន់រៀល* | *'ល្លារអាមេរិក* | *ពាន់រៀល* |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | | |
| ប្រាក់(ខាត )ចំណេញសម្រាប់ការិយបរិច្ឆេទ | (208,468) | (849,924) | 203,654 | 825,206 | 220,564 | 892,182 |
| *និយ័តភាពលើ៖* | | | | | | |
| ចំណាយពន្ធអប្បបរមា | 17,823 | 72,664 | | | | |
| ពន្ធលើប្រាក់ចំណេញ | 3,928 | 16,014 | 53,216 | 215,631 | 10,433 | 42,201 |
| ការខាតបង់/(តំហយ )លើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ | 69,516 | 283,417 | (17,310) | (70,140) | 29,485 | 119,267 |
| រំលស់លើទ្រព្យ និងបរិក្ខារ | 6,320 | 25,767 | 6,116 | 24,782 | 4,126 | 16,690 |
| រំលស់លើទ្រព្យសកម្មអរូបី | 2,096 | 8,545 | 2,096 | 8,493 | 2,096 | 8,478 |
| | **(108,785)** | **(443,517)** | **247,772** | **1,003,972** | **266,704** | **1,078,818** |
| *បម្រែបម្រួល៖* | | | | | | |
| ឥណទានផ្តល់ដល់អតិថិជន | 2,240,925 | 9,136,251 | (194,860) | (789,573) | (184,999) | (721,011) |
| ទ្រព្យសកម្មផ្សេងៗ | (25,814) | (105,244) | 75,895 | 307,527 | (36,861) | (148,107) |
| បំណុលផ្សេងៗ | (30,081) | (122,640) | 7,012 | 28,413 | (12,460) | (50,064) |
| | 2,076,245 | 8,464,850 | 135,819 | 550,339 | 32,384 | 159,636 |
| ពន្ធអប្បបរមានិងពន្ធលើប្រាក់ចំណេញដែលបានបង់ | (47,754) | (194,693) | (50,995) | (206,632) | (25,371) | (101,941) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ** | **2,028,491** | **8,270,157** | **84,824** | **343,707** | **7,013** | **57,695** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (3,615) | (14,738) | (10,512) | (42,595) | (16,920) | (67,985) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | **(3,615)** | **(14,738)** | **(10,512)** | **(42,595)** | **(16,920)** | **(67,985)** |
| **ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | **2,024,876** | **8,255,419** | **74,312** | **301,112** | **(9,907)** | **(10,290)** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី 1 ខែ មករា | 435,455 | 1,774,479 | 361,143 | 1,451,073 | 371,050 | 1,497,929 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (77,860) | - | 22,294 | - | (36,566) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី 31 ខែ ធ្នូ** | **2,460,331** | **9,952,038** | **435,455** | **1,774,479** | **361,143** | **1,451,073** |

## ២៧.៦ របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | ដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញ | | លម្អៀងពការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ហ្វូរអាមេរិក | ពាន់រៀល | អាមេរិក | ពាន់រៀល | 'ល្លារអាមេរិក | ពាន់រៀល |
| **នាថ្ងៃទី 1 ខែមករា ឆ្នាំ2019** | **1,500,000** | **6,000,000** | **88,727** | **358,901** | **114,415** | **462,809** | **-** | **21,515** | **1,703,142** | **6,843,225** |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | | | |
| ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ | - | - | - | - | 203,654 | 825,206 | - | - | **203,654** | **825,206** |
| ការផ្ទេរ | - | - | 26,896 | 109,603 | (26,896) | (109,603) | - | - | **-** | **-** |
| *លទ្ធផលលម្អិតផ្សេងៗ* | | | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | 101,762 | **-** | **101,762** |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | 26,896 | 109,603 | 176,758 | 715,603 | - | 101,762 | **203,654** | **926,968** |
| **នាថ្ងៃទី 31 ខែធ្នូ ឆ្នាំ2019** | **1,500,000** | **6,000,000** | **115,623** | **468,504** | **291,173** | **1,178,412** | **-** | **123,277** | **1,906,796** | **7,770,193** |
| **នាថ្ងៃទី 1 ខែមករា ឆ្នាំ2020** | 1,500,000 | 6,000,000 | 115,623 | 468,504 | 291,173 | 1,178,412 | - | 123,277 | **1,906,796** | **7,770,193** |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | | | |
| ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ | - | - | - | - | (208,468) | (849,924) | - | - | **(208,468)** | **(849,924)** |
| ការផ្ទេរ | - | - | (30,742) | (125,335) | 30,742 | 125,335 | - | - | **-** | **-** |
| *លទ្ធផលលម្អិតផ្សេងៗ* | | | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 175 | - | - | - | (50,707) | **-** | **(50,532)** |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | (30,742) | (125,160) | (177,726) | (724,589) | - | (50,707) | **(208,468)** | **(900,456)** |
| **នាថ្ងៃទី 31 ខែធ្នូ ឆ្នាំ2020** | **1,500,000** | **6,000,000** | **84,881** | **343,344** | **113,447** | **453,823** | **-** | **72,570** | **1,698,328** | **6,869,737** |

## ២៨. អាសយដ្ឋានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទ្រព្យខ្ញុំ ម.ក

TROP KHNHOM ទ្រព្យខ្ញុំ

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទ្រព្យខ្ញុំ មក

## ការិយាល័យកណ្តាល

ផ្ទះលេខ 455, ផ្លូវលេខ 4, ក្រុម 18, ភូមិសូភី, សង្កាត់កំពង់ស្វាយ, ក្រុងសិរីសោភ័ណ្ឌ, ខេត្តបន្ទាយមានជ័យ

Tel: (855) 81 646 494, (855) 12 58 30 77, (855) 17 38 87 87
E-mail: dann_shp@yahoo.com
Website: www.tropkhnhom.com.kh